ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១២ - ២០១៤

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ

នាថ្ងៃទី១៣ ខែមករា ឆ្នាំ២០១២

រៀបចំដោយក្រសួងផែនការ

# បុព្វកថា

*សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន* នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍បញ្ជាក់ឱ្យដឹងថា **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) បច្ចុប្បន្នកម្ម ២០០៩-២០១៣** គឺជាឯកសារសំខាន់មួយសម្រាប់គ្រប់គ្រងរាល់ការវិនិយោគ អភិវឌ្ឍន៍លើវិស័យសាធារណៈ នៅព្រះរាជាណាចក្រកម្ពុជា។

ចាប់តាំងពីឆ្នាំ១៩៩៦ ក្រសួងផែនការជាអ្នកទទួលខុសត្រូវក្នុងការរៀបចំ **កម្មវិធីវិនិយោគសាធារណៈ (កវស) ៣ឆ្នាំរំកិល** ជារៀងរាល់ឆ្នាំ ដើម្បីឆ្លើយតបទៅនឹងអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់តម្រូវការជំនួយវិនិយោគជាទុន និងជំនួយបច្ចេកទេសក្នុងការអនុវត្ត **ផយអជ** ។ ក្នុងការរៀបចំ **កវស ៣ឆ្នាំរំកិល** ឆ្នាំ ២០០៦-២០០៨ ឆ្នាំ ២០០៧-២០០៩ ឆ្នាំ ២០០៨-២០១០ ឆ្នាំ ២០០៩-២០១១ ឆ្នាំ ២០១០-២០១២ ឆ្នាំ ២០១១-២០១៣ និង ឆ្នាំ ២០១២-២០១៤ គឺការវិភាជថវិកាបានឆ្លើយតទៅនឹងការវិភាជដែលមានចែងនៅក្នុង **ផយអជ ២០០៦-២០១០** និង **ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣** ។

ក្រសួងផែនការបានធ្វើការកែសម្រួលបន្ថែមទៀតលើដំណើរការរៀបចំ **កវស ៣ឆ្នាំរំកិល ២០១២-២០១៤** ដោយបានរៀបចំការធ្វើការពិភាក្សាដោយផ្ទាល់ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបណ្តាក្រសួង ស្ថាប័ននីមួយៗ ដើម្បីធានាថា ការផ្ញើទិន្នន័យគម្រោងរបស់បណ្តាក្រសួង ស្ថាប័នទាំងអស់សម្រាប់រៀបចំ កវស ៣ឆ្នាំរំកិល ២០១២-២០១៤ បានឆ្លើយតបទៅនឹងអាទិភាពរបស់ **ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣**។

**ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣** បានបញ្ជាក់យ៉ាងច្បាស់លាស់ពីទំនាក់ទំនងនៃ **ផយអជ កវស ៣ឆ្នាំរំកិល ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងថវិកាប្រចាំឆ្នាំ** ។ បច្ចុប្បន្ន ថ្នាក់ដឹកនាំជាន់ខ្ពស់របស់ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា បាននិងកំពុងសម្របសម្រួលនិងប្រឹងប្រែងទាំងអស់គ្នា ដើម្បីធានាបាននូវសុខដុមនីយកម្មការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងគ្រប់គ្រងហិរញ្ញប្បទាន។

ខ្ញុំមានសេចក្តីរីករាយ និងសូមធ្វើការបង្ហាញនូវ **កវស ៣ឆ្នាំរំកិល ២០១២-២០១៤** សម្រាប់ជាព័ត៌មាន និងការប្រើប្រាស់របស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងដៃគូអភិវឌ្ឍន៍។ ក៏សូមឆ្លៀតយកឱកាសនេះ ដើម្បីបញ្ជាក់ឡើងវិញម្តងទៀតនិងជំរុញដល់ដៃគូអភិវឌ្ឍន៍ដែលផ្តល់ការជួយឧបត្ថម្ភគាំទ្រដល់ប្រទេសកម្ពុជា ត្រូវមានមូលដ្ឋានពិនិត្យលើគម្រោង **សម្រាប់អនុវត្ត ផយអជ** នៃបញ្ជីគម្រោង កវស ៣ឆ្នាំរំកិល ២០១២-២០១៤ ដែលនឹងនាំយើងឈានទៅសម្រេចបាននូវគោលបំណងនិងអាទិភាព ដែលមានចែងនៅក្នុង **ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣** និងដើម្បីកាត់បន្ថយភាពក្រីក្រនិងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

*ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ*

*ក្រសួងផែនការ*

*ខែមករា ឆ្នាំ២០១២*

**ឆាយ ថន**

# សញ្ញាជាតិនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា





# មាតិកា

ទំព័រ

បុព្វកថា ............................................................................................................ i
សញ្ញាជាតិនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា ................................................................ ii
មាតិកា ............................................................................................................ iii

ជំពូកទី១. សេចក្តីផ្តើម

ដំណើរការសុខដុមនីយកម្មការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋនិងហិរញ្ញប្បទានសហប្រតិបត្តិការ ........................................................................ ១
វិធីសាស្រ្តសម្រាប់រៀបចំកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល២០១២-២០១៤ .............. ២

ជំពូកទី២. ទស្សនវិស័យសេដ្ឋកិច្ចឆ្នាំ២០១២-២០១៤ ...................................... ៦

ស្ថានភាពទូទៅនៃកំណើនផលិតផលក្នុងស្រុកសរុប ២០១២-២០១៤ .......................... ៦
អត្រាកំណើន ផសស ពិត(ថ្លៃថេរឆ្នាំ២០០០)ដោយសកម្មភាពសេដ្ឋកិច្ច............................៨
ការវិនិយោគដែលចាំបាច់ដើម្បីសម្រេចនូវកំណើន ផសស ដែលបានគ្រោងទុក ............ ៩
ចំណូលនិងចំណាយថវិកា២០១២-២០១៤..................................................... ១២
ចំណុចដៅនៃការកៀរគរធនធានសម្រាប់ការវិនិយោគរបស់វិស័យសាធារណៈឆ្នាំ២០១២-២០១៤ ........................................................................................ ១៣

ជំពូកទី៣. កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល២០១២-២០១៤ .............. ១៧

ជំពូកទី៤. សេចក្តីសន្និដ្ឋាន ............................................................................ ៣៨

# បញ្ជីតារាង

តារាងទី១ ការព្យាករពីសូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច ................................................ ៧
តារាងទី២ អត្រាកំណើន ផសស(ថ្លៃថេរឆ្នាំ២០០០)ដោយសកម្មភាពសេដ្ឋកិច្ច .......................... ៨
តារាងទី៣ ការវិនិយោគមូលធនចាំបាច់ដើម្បីសម្រេចបានកំណើន ផសស ដែលបានគ្រោងទុកនិងធនធានដែលអាចមានសម្រាប់ធ្វើហិរញ្ញប្បទានដល់ការវិនិយោគចាំបាច់ ....................... ១០
តារាងទី៤ វិនិយោគមូលធនដែលត្រូវការតាមវិស័យនីមួយៗ ដើម្បីសម្រេចបាននូវគោលដៅនៃកំណើន ផសស ................................................................................................ ១១

តារាងទី៥ ចំណុចដៅនៃការកៀរគរធនធានសម្រាប់ការវិនិយោគរបស់វិស័យសាធារណៈឆ្នាំ ២០១២-២០១៤ ........ ១៤
តារាងទី៦ ការវិភាជតាមវិស័យនិងអនុវិស័យសម្រាប់តម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈ ដោយមានមូលដ្ឋានពីការវិភាជតាមវិស័យនិងអនុវិស័យ ចែងនៅក្នុង ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ........ ១៥
តារាងទី៧ វិភាជតាមវិស័យនិងអនុវិស័យ សម្រាប់តម្រូវការវិនិយោគវិស័យសាធារណៈ ចែងនៅក្នុង ផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣និង កវស បីឆ្នាំរំកិល២០១២-២០១៤ ........ ១៧
តារាងទី៨ សេចក្តីសង្ខេបស្តីពីគម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្ត ផយអជ ដែលក្រសួង ស្ថាប័នស្នើសុំសម្រាប់ កវស បីឆ្នាំរំកិល២០១២-២០១៤ ........ ២០
តារាងទី៩ គម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្ត ផយអជ បែងចែកតាមវិស័យអាទិភាពនៃផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣ ដែលក្រសួង ស្ថាប័នស្នើសុំ ........ ២១
តារាងទី១០ បរិមាណខុសគ្នានៃការវិភាជតាមអនុវិស័យ ផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣ និងការស្នើសុំដោយក្រសួង ស្ថាប័ន ........ ៣៣
តារាងទី១១ សេចក្តីសង្ខេបការវិភាជតាមវិស័យក្នុង ផយអជ បច្ចុប្បន្នកម្ម និងចំណាយប៉ាន់ស្មានតាមក្រសួង ស្ថាប័ន ........ ៣៤
តារាងទី១២ បញ្ជីគម្រោងបែងចែកតាមក្រសួង ស្ថាប័ន ........ ៣៩
តារាងទី១៣ បញ្ជីគម្រោងតាមវិស័យ ផយអជ បច្ចុប្បន្នកម្ម និងក្រសួង ស្ថាប័ន ........ ៩៩

# ជំពូកទី១
# សេចក្តីផ្តើម

១.  គោលបំណងសំខាន់នៃ*កម្មវិធីវិនិយោគសាធារណៈ(កវស)  បីឆ្នាំរំកិល២០១២-២០១៤* គឺធ្វើការបង្ហាញពីទិន្នន័យគម្រោងវិនិយោគដែលមានអាទិភាពខ្ពស់របស់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា ដែលជាគោលនយោបាយមានចែងនៅក្នុង *យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី២* និងជាផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្តគោលនយោបាយដែលមានចែងក្នុង *ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ(ផយអជ)បច្ចុប្បន្នកម្ម២០០៩-២០១៣*។ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ដែលបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០១០ ត្រូវបានរៀបចំឡើងដោយមានមូលដ្ឋានពីធាតុចូលរបស់ក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាលកម្ពុជា។

២.  *កវស បីឆ្នាំរំកិល* បានដាក់បញ្ចូលគ្នា *គម្រោងកំពុងដំណើរការ* ដែលការអនុវត្តគម្រោងកំពុងបន្តនៅក្នុងដំណាក់កាល កវស និង*គម្រោងសម្រាប់អនុវត្ត ផយអជ* ជាគម្រោងស្នើសុំថ្មីដែលត្រូវនឹងការអនុវត្តក្នុងដំណាក់កាល កវស។

ប្រភពទិន្នន័យសម្រាប់រៀបចំ កវស រួមមាន៖

(i) ព័ត៌មានស្តីពី *គម្រោងកំពុងដំណើរការ* ក្នុងនោះ គម្រោងកំពុងដំណើរការក្នុងក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការ ត្រូវបានផ្តល់ដោយគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កាលពីខែមីនា ឆ្នាំ២០១១ និងពិនិត្យកែសម្រួលដោយក្រសួង ស្ថាប័ន អនុវត្តគម្រោងរបស់រាជរដ្ឋាភិបាលកម្ពុជា។ និង

(ii) ព័ត៌មានស្តីពី *គម្រោងសម្រាប់អនុវត្ត ផយអជ* ដែលក្រសួងផែនការបានទទួលពីក្រសួង ស្ថាប័ន ទាំងអស់សម្រាប់រៀបចំ *កវស បីឆ្នាំរំកិល២០១២-២០១៤*។

## *១.  ដំណើរការនៃការងារដឹកនាំដំណើរការសុខដុមនីយកម្ម ការងារផែនការចំណាយវិនិយោគសាធារណៈរបស់រដ្ឋនិងហិរញ្ញប្បទានសហប្រតិបត្តិការ*

៣.  នៅពាក់កណ្តាលឆ្នាំ២០០៩ ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចបង្កើត *ក្រុមការងារដឹកនាំដំណើរការសុខដុមនីយកម្ម ការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ* ដើម្បីពង្រឹងការងារសុខដុមនីយកម្ម ការងារផែនការ និងការអនុវត្តជាក់ស្តែង ដែលជាគោលដៅសំខាន់នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២។

៤.  បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាកំពុងធ្វើការពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីភ្ជាប់ទំនាក់ទំនងនៃដំណើរការ៖

(i) កំណត់តម្រូវការជាអាទិភាពសម្រាប់វិនិយោគតាមរយៈកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ដែលរៀបចំឡើងដោយក្រសួងផែនការ។

(ii) រៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

(iii) រៀបចំទិន្នន័យនៃគម្រោងវិនិយោគមូលធន ដែលកំពុងដំណើរការរបស់នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ និង

(iv) រៀបចំទិន្នន័យនៃគម្រោងកំពុងដំណើរការនិងការវិភាជធនធានរបស់ដៃគូអភិវឌ្ឍនានា ដោយគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

៥. **ក្រុមការងារដឹកនាំដំណើរការសុខដុមនីយកម្ម ការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ**នេះដឹកនាំដោយក្រសួងផែនការ និងមានសមាជិកមកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ក្រុមការងារបានរៀបចំកិច្ចប្រជុំជាច្រើនដងដើម្បីពិភាក្សានិងកំណត់ទិសដៅការងាររបស់ខ្លួន។ បច្ចុប្បន្ននេះ មានក្របខ័ណ្ឌការងាររួមមួយសម្រាប់ការតាមដានត្រួតពិនិត្យការងាររបស់ក្រុមការងារ ត្រូវបានកំណត់ជាសូចនាករសម្រាប់ការតាមដានរួមគ្នា (JMIs) សម្រាប់សកម្មភាពនេះ។ តាមរយៈសូចនាករសម្រាប់ការតាមដានរួមគ្នា ពេលនេះក្រុមការងារកំពុងដំណើរការធ្វើការវិភាគស្ថានភាពលើការងាររបស់ខ្លួន ដែលនឹងត្រូវសម្រេចដោយ*គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* និងរៀបចំផែនការសកម្មភាពនៅក្នុងឆ្នាំ២០១២។

## *២. វិធីសាស្ត្រសម្រាប់ការរៀបចំកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល២០១២-២០១៤*

៦. សម្រាប់ការរៀបចំ*កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល២០១២-២០១៤* ក្រសួងផែនការបាននិងកំពុងធ្វើកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីឈានទៅសម្រេចបាននូវ*សុខដុមនីយកម្ម ការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ និងដើម្បីពង្រឹងយន្តការស្ថាប័ននៃការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព*។

៧. វិធីសាស្ត្រសម្រាប់ការរៀបចំ*កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល២០១២-២០១៤* ត្រូវបានធ្វើការកែលំអបន្ថែមទៀតលើ*កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល២០១១-២០១៣*។ វិធីសាស្ត្រថ្មីនេះ រួមមាន ***គម្រោងកំពុងដំណើរការ*** គឺជាគម្រោងដែលកំពុងត្រូវបានអនុវត្តឬមានកិច្ចសហការនិងការសម្របសម្រួលជាមួយស្ថាប័នរបស់រាជរដ្ឋាភិបាល ហើយការអនុវត្តគម្រោងទាំងនោះនឹងត្រូវបន្តនៅក្នុងអំឡុងពេលនៃ កវស បីឆ្នាំរំកិល២០១២-២០១៤ និង***គម្រោងសម្រាប់អនុវត្ត ផយអជ ឬគម្រោងថ្មី*** ដែលនឹងត្រូវអនុវត្តក្នុងអំឡុងពេលនៃ កវស បីឆ្នាំរំកិល ២០១២-២០១៤។ គម្រោងកំពុងដំណើរការ គឺត្រូវបានដាក់បញ្ចូលនូវគម្រោងដែលកំពុងអនុវត្ត

ដោយអង្គការមិនមែនរដ្ឋាភិបាល/សង្គមស៊ីវិលនានា ដោយសហការជាមួយក្រសួង ស្ថាប័ន តាមវិស័យពាក់ព័ន្ធ។ ព័ត៌មានសម្រាប់ការរៀបចំ កវស បីឆ្នាំរំកិល២០១២-២០១៤ ត្រូវបានធ្វើការកែលំអតាមរយៈកម្រងបញ្ជីសំណួរថ្មី ដែលបានចែកចេញជាពីរផ្នែក។ **ផ្នែកទី១** គឺការប្រមូលព័ត៌មានស្តីពី ***គម្រោងសម្រាប់អនុវត្ត ផយអជ*** និង **ផ្នែកទី២** គឺការប្រមូលព័ត៌មាន ស្តីពី ***គម្រោងកំពុងដំណើរការ*** ដែលបញ្ជីសំណួរ កវស បីឆ្នាំរំកិលថ្មីមានបង្ហាញក្នុងឧបសម្ព័ន្ធ១។

៨. សម្រាប់ការរៀបចំ កវស បីឆ្នាំរំកិល២០១២-២០១៤ និងតាមសំណើរបស់ក្រសួងផែនការ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជាបានផ្ញើមកក្រសួងផែនការនូវព័ត៌មានស្តីពី *ការចំ-ណាយជំនួយអភិវឌ្ឍផ្លូវការទៅតាមគម្រោងនិងក្រសួង ស្ថាប័នដែលរាយការណ៍ដោយដៃគូអភិវឌ្ឍជារៀងរាល់ឆ្នាំ*។ គម្រោងកំពុងដំណើរការទាំងអស់ដែលរាយការណ៍ដោយដៃគូអភិវឌ្ឍគឺជាបណ្តាគម្រោងដែលកំពុងអនុវត្តដោយៈ (i) ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល (ii) ដៃគូអភិវឌ្ឍ និង (iii) អង្គការមិនមែនរដ្ឋាភិបាល/សង្គមស៊ីវិល ដោយមានការគាំទ្រផ្តល់ថវិកាពីដៃគូអភិវឌ្ឍ។

៩. ប្រភពទិន្នន័យសំខាន់សម្រាប់ការរៀបចំ កវស បីឆ្នាំរំកិល២០១២-២០១៤ គឺក្រសួងផែនការបានទទួលពីគ្រប់ក្រសួង ស្ថាប័ន។ ក្រសួងផែនការបានទទួលស្គាល់ថា ក្រសួង ស្ថាប័ន ផ្តល់តែព័ត៌មានសម្រាប់ *គម្រោងកំពុងដំណើរការ* ដែលកំពុងអនុវត្តដោយមានឬពុំមានកិច្ចសហការជាមួយក្រសួង ស្ថាប័ន របស់ខ្លួននីមួយៗ។ តាមរយៈការអនុវត្តជាក់ស្តែង យើងទទួលស្គាល់ថាទិន្នន័យស្តីពីគម្រោងកំពុងដំណើរការដែលក្រសួង ស្ថាប័នផ្ញើមកក្រសួងផែនការ មានដាក់បញ្ចូលនូវគម្រោងកំពុងដំណើរការមួយចំនួន ដែលដៃគូអភិវឌ្ឍបានរាយការណ៍ជូនគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា។ ប៉ុន្តែ ដើម្បីធានាបាននូវការកត់ត្រាច្បាស់លាស់នូវចំនួនគម្រោងកំពុងដំណើរការដែលកំពុងអនុវត្តដោយមានឬពុំមានកិច្ចសហការជាមួយក្រសួង ស្ថាប័ននីមួយៗ និងដើម្បីជួយសម្រួលដល់ការរៀបចំទិន្នន័យគម្រោងកំពុងដំណើរការរបស់ក្រសួង ស្ថាប័ន ក្រសួងផែនការបានផ្ញើបញ្ជីគម្រោងកំពុងដំណើរការដែលបានទទួលពី គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជាទៅគ្រប់ក្រសួង ស្ថាប័ន ដើម្បីពិនិត្យនិងដាក់បញ្ចូលសម្រាប់ការរៀបចំ កវស បីឆ្នាំរំកិល២០១២-២០១៤។

១០. ចំពោះ*គម្រោងសម្រាប់អនុវត្ត ផយអជ(គម្រោងថ្មី)* ដែលនឹងត្រូវអនុវត្តក្នុងអំឡុងឆ្នាំ ២០១២-២០១៤ ក្រសួងផែនការបានផ្តល់សេចក្តីណែនាំនិងពន្យល់ដោយផ្ទាល់ដល់គ្រប់ក្រសួង ស្ថាប័ន បន្ថែមពីលើការពន្យល់តាមរយៈសិក្ខាសាលាជាតិនាពេលកន្លងមក ដើម្បីធានាថាក្នុងការស្នើសុំ *គម្រោងសម្រាប់អនុវត្ត ផយអជ* ក្រសួង ស្ថាប័នទាំងអស់បានៈ

(i) គិតច្បាស់លាស់ពីសារៈសំខាន់នៃគម្រោងទាំងនោះ ក្នុងការគាំទ្រដល់គោលដៅអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចរបស់រាជរដ្ឋាភិបាល ដើម្បីឈានទៅសម្រេចបាននូវគោល

នយោបាយជាអាទិភាពនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ ព្រមទាំងផែនការរបស់ក្រសួង ស្ថាប័ន ដែលមានចែងនៅក្នុង ផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣។

(ii) ពិនិត្យច្បាស់លាស់ការវិភាជតាមវិស័យអាទិភាពដែលមានចែងនៅក្នុង ផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣។

(iii) ពិនិត្យលទ្ធផលនៃកិច្ចពិភាក្សារវាងមន្ត្រីរបស់ក្រសួង ស្ថាប័ន នីមួយៗ និងនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការរៀបចំ *ផែនការយុទ្ធសាស្ត្រថវិកា* រយៈពេលវែងសម្រាប់ក្រសួង ស្ថាប័នរបស់ខ្លួន។

(iv) ពិនិត្យច្បាស់លាស់ពីប្រភពធនធានជាសក្តានុពលក្នុងការផ្តល់ហិរញ្ញប្បទានដល់គម្រោងសម្រាប់អនុវត្ត ផយអជ។

(v) កំណត់ *លំដាប់អាទិភាព* ចំពោះគម្រោងសម្រាប់អនុវត្ត ផយអជ នីមួយៗ ដែលក្រសួង ស្ថាប័នបានផ្ញើមកក្រសួងផែនការ។ នាពេលសិក្ខាសាលាជាតិស្តីពីការផ្សព្វផ្សាយដំណើរការនៃការរៀបចំ *កវស បីឆ្នាំរំកិល២០១១-២០១៣* ក្រសួងផែនការបានបញ្ជាក់ច្បាស់ថា៖

- អាទិភាពគម្រោងមិនអាចមានលំដាប់ដូចគ្នានៅក្នុងក្រសួង ស្ថាប័ន តែមួយ
- ចំពោះករណីគម្រោងអភិក្រមគ្រប់គ្រងទូទាំងវិស័យឬកម្មវិធីធំ ត្រូវផ្តល់ព័ត៌មានស្តីពីផ្នែកទាំងឡាយនៃគម្រោងដែលអាចទទួលបានហិរញ្ញប្បទានជាគម្រោង ព្រមទាំងគម្រោងតាមផ្នែកផ្សេងៗទៀតដែលត្រូវការនូវការកំណត់លំដាប់អាទិភាពដោយផ្អែកលើរយៈពេលនៃការអនុវត្តសកម្មភាពអភិក្រមគ្រប់គ្រងទូទាំងវិស័យឬសកម្មភាពដែលបានកំណត់របស់កម្មវិធីធំៗ
- ក្រសួងផែនការនឹងធ្វើការផ្តល់លេខគម្រោងដល់គ្រប់គម្រោង *កវស បីឆ្នាំរំកិល*ទាំងអស់ដែលថ្នាក់ដឹកនាំក្រសួង ស្ថាប័នបានកំណត់អាទិភាពនិងផ្ញើមកក្រសួងផែនការ។

១១. ក្រសួងផែនការធ្វើការវិភាជថវិកាសម្រាប់ *កវស បីឆ្នាំរំកិល២០១២-២០១៤* ដោយមានមូលដ្ឋាននៃលក្ខណវិនិច្ឆ័យ ដូចខាងក្រោម៖

- ការវិភាជសរុបសម្រាប់វិស័យដល់ *គម្រោងកំពុងដំណើរការ* និង *គម្រោងសម្រាប់អនុវត្ត ផយអជ* ត្រូវមានសង្គតិភាពជាមួយការវិភាជតាមវិស័យដែលមានចែងនៅក្នុង *ផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣*។
- អាទិភាពទីមួយ គឺការវិភាជថវិកាដែលមានដល់បណ្តាគម្រោងកំពុងដំណើរការដើម្បីបន្តការអនុវត្តនិងបញ្ចប់ការអនុវត្ត។
- តុល្យភាពថវិកាដែលនៅសល់នឹងត្រូវធ្វើការវិភាជដល់គម្រោងសម្រាប់អនុវត្ត *ផយអជ* ដោយផ្អែកលើ៖
    - អាទិភាពនៃគម្រោងដែលកំណត់ដោយក្រសួង ស្ថាប័ន។

- គម្រោងសម្រាប់អនុវត្ត ផយអជ ទាំងនោះសម្រាប់អនុវត្តយុទ្ធសាស្ត្រតាមវិស័យរបស់ក្រសួង ស្ថាប័ន ដើម្បីអនុវត្តគោលនយោបាយអាទិភាពនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ និងអាទិភាពដែលមានចែងនៅក្នុង *ផយអជ បច្ចុប្បន្ន ២០០៩-២០១៣*។
- ព័ត៌មានដែលក្រសួង ស្ថាប័ន បានផ្ញើមកក្រសួងផែនការស្តីពីស្ថានភាពសក្តានុពលក្នុងការសន្យាផ្តល់ហិរញ្ញប្បទានដល់គម្រោងសម្រាប់អនុវត្ត *ផយអជ*។
- កិច្ចពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងកែសម្រួលឡើងវិញនូវការសន្យាផ្តល់ថវិកាពីកញ្ចប់ថវិកាជាតិ និងលទ្ធផលនៃកិច្ចពិភាក្សារវាងក្រសួង ស្ថាប័ន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការរៀបចំ *ផែនការយុទ្ធសាស្ត្រថវិកា* សម្រាប់ក្រសួង ស្ថាប័ននីមួយៗ។

១២. ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃ *កវស បីឆ្នាំរំកិល* ក្រសួងផែនការបានរៀបចំកែសម្រួលឡើងវិញនូវប្រព័ន្ធទិន្នន័យរបស់ *កវស បីឆ្នាំរំកិល* និងបញ្ជីសំណួរ រួចផ្ញើទៅក្រសួង ស្ថាប័នទាំងអស់ សម្រាប់ឲ្យមន្ត្រីរបស់ក្រសួង ស្ថាប័នទាំងនោះបំពេញតាមប្រព័ន្ធកុំព្យូទ័រ និងផ្ញើត្រឡប់មកក្រសួងផែនការវិញ។

១៣. នៅក្នុង *កវស បីឆ្នាំរំកិល* ឆ្នាំមុនៗ(មុន *កវស បីឆ្នាំរំកិល២០១១-២០១៣*) ក្រសួងផែនការបានរៀបចំរបាយការណ៍វាយតម្លៃលើស្ថានភាពនៃការអនុវត្តគម្រោង *កវស បីឆ្នាំរំកិល* នៅឆ្នាំមុន។ ប៉ុន្តែ បច្ចុប្បន្ននេះ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជាបានរៀបចំរបាយការណ៍ស្តីពីប្រសិទ្ធភាពជំនួយដែលរួមមានការវិភាគលើការបន្ស៊ីធនធានដែលបានផ្តល់ជាមួយនឹងការវិភាជតាមវិស័យមានចែងនៅក្នុង *ផយអជ*។ ដូច្នេះ *កវស បីឆ្នាំរំកិល២០១២-២០១៤* ក៏នឹងមិនដាក់បញ្ចូលនូវរបាយការណ៍វាយតម្លៃលើស្ថានភាពនៃការអនុវត្តគម្រោង *កវស បីឆ្នាំរំកិល* នៅឆ្នាំមុនទៀតដែរ។

១៤. បន្ទាប់ពីសេចក្តីផ្តើមនៃ *កវស បីឆ្នាំរំកិល២០១២-២០១៤* នឹងមានបង្ហាញពីព័ត៌មានស្តីពីទស្សនវិស័យសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១២-២០១៤ ក្នុងជំពូកទី២។ ជំពូកទី៣ បង្ហាញពីព័ត៌មានស្តីពី *កវស បីឆ្នាំរំកិល២០១២-២០១៤* និងជំពូកទី៤ បង្ហាញពីសេចក្តីសន្និដ្ឋាន។

# ជំពូកទី២
# ទស្សនវិស័យសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១២-២០១៤

## ១. ស្ថានភាពទូទៅនៃកំណើនផលិតផលក្នុងស្រុកសរុប២០១២-២០១៤

១៥. វិបត្តិហិរញ្ញវត្ថុសកលលោកនិងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចសកលលោកដែលចាប់ផ្តើមក្នុងឆ្នាំ២០០៧ នៅក្នុងប្រទេសអភិវឌ្ឍជាច្រើន បានជះឥទ្ធិពលនិងប៉ះពាល់ដល់វិស័យសំខាន់ៗមួយចំនួននៃសេដ្ឋកិច្ចរបស់កម្ពុជា ដែលធ្វើឲ្យកំណើនផលិតផលក្នុងស្រុកសរុប(ផសស)បានធ្លាក់ចុះពី៦,៧ភាគរយក្នុងឆ្នាំ២០០៨មកនៅត្រឹមតែ០,១ភាគរយក្នុងឆ្នាំ២០០៩។ ក្នុងអំឡុងពេលវិបត្តិនេះ វិស័យកសិកម្មនិងសេវាកម្មនៅរក្សាកំណើនបានយ៉ាងល្អដែលបានជួយបំពេញនូវការធ្លាក់ចុះក្នុងវិស័យមួយចំនួនទៀត ជាពិសេសវិស័យឧស្សាហកម្ម។ លំហូរនៃការវិនិយោគផ្ទាល់ពីបរទេសក៏បានធ្លាក់ចុះយ៉ាងច្រើនក្នុងទំហំប្រមាណ៥០០លានដុល្លារអាមេរិកនៅឆ្នាំ២០០៩។ ដោយមានការឆ្លើយតបទាន់ពេលវេលារបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះវិបត្តិហិរញ្ញវត្ថុសកលលោកនិងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចសកលលោកនិងសេដ្ឋកិច្ចតំបន់ ទើបហានិភ័យនិងឥទ្ធិពលអវិជ្ជមានលើកំណើនសេដ្ឋកិច្ចព្រមទាំងលើសុខុមាលភាពរបស់ប្រជាជនយើង ជាពិសេសប្រជាជនក្រីក្រនិងប្រជាជនងាយរងគ្រោះត្រូវបានកាត់បន្ថយ។

១៦. ទោះបីរាជរដ្ឋាភិបាលបានខិតខំដឹកនាំសេដ្ឋកិច្ច បានទប់ទល់ទៅនឹងវិបត្តិហិរញ្ញវត្ថុសកលលោកនិងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចសកលលោក បានលទ្ធផលគួរជាទីកត់សម្គាល់ដោយសារតែមានក្របខ័ណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញពីទសវត្សរ៍មុននិងការអនុវត្តវិធានការគោលនយោបាយសម្រាប់កាត់បន្ថយផលប៉ះពាល់នៃវិបត្តិ ក៏គម្លាតនៃលទ្ធផលនិងអត្រាអត់ការងារធ្វើអាចនឹងបន្តកើនឡើង។ ដោយពិចារណាពីកត្តាអភិវឌ្ឍទាំងនេះ កម្រិតនៃសកម្មភាពសេដ្ឋកិច្ចនឹងមានកំណើនបន្តិចម្តងៗ ដែលតាមការប៉ាន់ស្មានអាចកើនឡើងប្រមាណ៥,៩ភាគរយក្នុងឆ្នាំ២០១០ ហើយអត្រាកំណើនសេដ្ឋកិច្ចនឹងបន្តកើនឡើងវិញរហូតដល់៦,៥ភាគរយនៅឆ្នាំ២០១២ និងបន្តកើនឡើងដល់៧ភាគរយនៅឆ្នាំ២០១៤។ ការព្យាករពីសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ សម្រាប់ឆ្នាំ២០១១-២០១៤ មានបង្ហាញក្នុងតារាងទី១។

## តារាងទី១ ការព្យាករពីសូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច

| សូចនាករសេដ្ឋកិច្ច | ២០១១ | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|---|
| *ផសស* (ថ្លៃបច្ចុប្បន្ន គិតជាពាន់លានរៀល) | ៥១ ៤៥៤.៣ | ៥៦ ៧៣៥.៧ | ៦១ ៩៦៥.៧ | ៦៧ ៧០៥ |
| *ផសស* (ថ្លៃបច្ចុប្បន្ន-គិតជាលានដុល្លារ) | ១២ ៧០៤.៨ | ១៤ ០៧៦.២ | ១៦ ១០៦ | ១៧ ៦០៦ |
| *ផសស* សម្រាប់ប្រជាជនម្នាក់ៗ (គិតជាដុល្លារ) | ៨១២ | ៨៧៩.២ | ៩៤២ | ១ ០១០.៤ |
| **អត្រាកំណើន *ផសស ពិត* (%)** | **៦,០%** | **៦,៥%** | **៧%** | **៧%** |
| | | | | |
| **អតិផរណា (ការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ គិតជាភាគរយ)** | **៥,៥%** | **៥,០%** | **៣,០%** | **៣,០%** |
| | | | | |
| **ការវិនិយោគសរុប (% *ផសស*)** | **២៤,៧%** | **២៤,៥%** | **២៣,៨%** | **២៤,០%** |
| ការវិនិយោគសាធារណៈ (% *ផសស*) | ៨,២% | ៨,១% | ៧,៨% | ៧,៨% |
| ការវិនិយោគឯកជន (% *ផសស*) | ១៦,៥% | ១៦,៤% | ១៦,១% | ១៦,១% |
| | | | | |
| **ចំណូលថវិកាសរុប (% *ផសស*)** | **១៣,៤%** | **១៣,៨%** | **១៤,៣%** | **១៤,៨%** |
| **ចំណាយថវិកាសរុប (% *ផសស*)** | **១៩,៧%** | **១៩,៨%** | **១៩,៩%** | **១៩,៥%** |
| | | | | |

មានមូលដ្ឋានលើអត្រាប្តូរប្រាក់៤១០០រៀល = ១ដុល្លារអាមេរិក

*ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ*

១៧. រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា កំណើនការចំណាយសម្រាប់សម្ភារៈប្រើប្រាស់នៅក្នុងប្រទេសអភិវឌ្ឍ(អាមេរិកនិងសហគមន៍អឺរ៉ុប) នឹងមិនបានផ្តល់ការគាំទ្រដល់កំណើនសេដ្ឋកិច្ចដូចនៅកម្ពុជាទេ ដូចករណីដែលធ្លាប់មានពីមុនមក។ ប៉ុន្តែ រាជរដ្ឋាភិបាលមានទំនុកចិត្តយ៉ាងមុតមាំថា តាមរយៈការអនុវត្តគោលនយោបាយរបស់ខ្លួនក្នុងការពង្រីកមូលដ្ឋានកំណើនសេដ្ឋកិច្ចនិងភាពប្រកួតប្រជែងក្នុងទីផ្សារតំបន់និងទីផ្សារអន្តរជាតិ សេដ្ឋកិច្ចនឹងឆ្ពោះទៅរកកំណើនសេដ្ឋកិច្ចដែលធ្លាប់សម្រេចបានសម្រាប់ឆ្នាំ២០១២-២០១៤។ ក្នុងអំឡុងពេលនៃវិបត្តិហិរញ្ញវត្ថុសកលលោកនិងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចសកលលោក សេដ្ឋកិច្ចកម្ពុជានៅតែបង្ហាញពីភាពមិនទ្រុឌទ្រោមនិងភាពបត់បែនបាន។ រាជរដ្ឋាភិបាលកម្ពុជា មានជំនឿជឿជាក់ថា ការបន្តអនុវត្តដ៏ខ្លាំងក្លានូវនយោបាយរបស់ខ្លួននឹងអាចទាញយកប្រយោជន៍ពីសក្តានុពលសេដ្ឋកិច្ចនេះ ជាពិសេសការបង្កើននិងការពង្រឹងគុណភាពផលិតផលនិងសេវាកម្មរបស់ខ្លួនផ្ទាល់។

## ២. អត្រាកំណើន ផសស ពិត(ថ្លៃថេរឆ្នាំ២០០០)ដោយសកម្មភាពសេដ្ឋកិច្ច

១៨. តាមរយៈបទពិសោធដែលទទួលបានពីការធ្លាក់ចុះនៃសេដ្ឋកិច្ចក្នុងឆ្នាំ២០០៩ រាជរដ្ឋាភិបាលមានសង្ឃឹមថា កំណើនទទួលបានពីវិស័យឧស្សាហកម្មដែលធ្លាប់កើនឡើងពីរខ្ទង់នៅឆ្នាំ ២០១០ នឹងជាមូលដ្ឋានដែលជួយស្តារនូវកំណើន ផសស។ ការព្យាករពីអត្រាកំណើន ផសស ដោយសកម្មភាពសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១១-២០១៤ មានបង្ហាញក្នុងតារាងទី២។

**តារាងទី២ អត្រាកំណើន ផសស (ថ្លៃថេរឆ្នាំ២០០០) ដោយសកម្មភាពសេដ្ឋកិច្ច**

| | ២០១១ | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|---|
| **កសិកម្ម នេសាទ និងរុក្ខាប្រមាញ់** | **៤,១%** | **៤,២%** | **៣,៨%** | **៣,៧%** |
| ដំណាំ | ៤,១% | ៤,៤% | ៤,៣% | ៤,២% |
| ការចិញ្ចឹមសត្វ | ៥,០% | ៤,៩% | ៥,០% | ៥,០% |
| ការនេសាទ | ៤,៣% | ៣,៩% | ២,៤% | ២,៤% |
| រុក្ខាប្រមាញ់ | ១,១% | ១,១% | ១,១% | ១,១% |
| **ឧស្សាហកម្ម** | **៩,២%** | **៩,៤%** | **៩,៩%** | **៩,៣%** |
| រ៉ែ | ៨,៥% | ៧,៣% | ៨,៨% | ៨,៩% |
| កម្មន្តសាល | ៩,៩% | ៩,៦% | ១០,០% | ៩,២% |
| អាហារ ភេសជ្ជៈ និងថ្នាំជក់ | ៣,៦% | ៤,១% | ៥,៥% | ៥,៦% |
| វាយនភណ្ឌ សម្លៀកបំពាក់ | ១១,៦% | ១១,២% | ១១,២% | ១០,០% |
| ឈើ ក្រដាស និងការបោះពុម្ព | ១,៦% | ២,២% | ៣,៥% | ៣,៦% |
| ផលិតកម្មជ័រកៅស៊ូ | ៨,៨% | ៨,៣% | ៩,៧% | ៩,៩% |
| ផលិតកម្មផ្សេងៗទៀត | ៥,៦% | ៤,៤% | ៦,២% | ៦,៣% |
| អគ្គិសនី ឧស្ម័ន និងទឹក | ៦,៥% | ៦,៦% | ៧,៦% | ៧,៧% |
| សំណង់ | ៦,៧% | ៩,៣% | ១០,១% | ១០,២% |
| **សេវាកម្ម** | **៥,៧%** | **៥,៧%** | **៧,១%** | **៧,៣%** |
| ពាណិជ្ជកម្ម | ៥,៨% | ៤,៩% | ៦,៣% | ៦,៤% |
| សណ្ឋាគារនិងភោជនីយដ្ឋាន | ១០,៧% | ៩,៤% | ៩,៤% | ៩,៥% |
| ការដឹកជញ្ជូននិងទូរគមនាគមន៍ | ៤,២% | ៤,៤% | ៥,៨% | ៥,៩% |
| ហិរញ្ញវត្ថុ | ៧,៩% | ៧,៨% | ៨,៥% | ៨,៦% |
| រដ្ឋបាលសាធារណៈ | ៤,៦% | ៤,០% | ៣,៩% | ៤,០% |
| អចលនទ្រព្យនិងអាជីវកម្ម | ៥,១% | ៥,៩% | ៨,២% | ៨,២% |
| សេវាកម្មផ្សេងៗទៀត | ៤,៣% | ៤,៩% | ៧,០% | ៧,៤% |
| | | | | |
| ពន្ធលើផលិតផល ដោយមិនគិតបញ្ចូលនូវការឧបត្ថម្ភធន | ៣,៦% | ៩,១% | ៦,៦% | ៨,២% |
| ការឧបត្ថម្ភធន | ៤០,៣% | ៩,១% | ៦,៦% | ៨,២% |
| ថ្លៃសេវាកម្មហិរញ្ញវត្ថុ | ១៣,៩% | ៧,៨% | ៨,៥% | ៨,៦% |
| **ផសស សរុប** | **៦,០%** | **៦,៥%** | **៧,០%** | **៧,០%** |

## ៣. ការវិនិយោគដែលចាំបាច់ដើម្បីសម្រេចបាននូវកំណើន ផសស ដែលបានគ្រោងទុក

១៩. គំរូនៃសេដ្ឋកិច្ចវិទ្យាធ្លាប់ប្រើដើម្បីធ្វើការព្យាករពីសេដ្ឋកិច្ចសម្រាប់រយៈពេល៥ឆ្នាំ ពីឆ្នាំ ២០០៩ដល់២០១៣ ក៏អាចត្រូវបានប្រើប្រាស់ដើម្បីធ្វើការព្យាករពីការវិនិយោគសរុបដែលចាំបាច់ក្នុងការធ្វើឲ្យសម្រេចបាននូវ *កំណើន ផសស* ដូចដែលបានគ្រោងទុកនិងការបែងចែកនៃការវិនិយោគសរុបទៅតាមវិស័យសេដ្ឋកិច្ច។ ថ្វីបើភាពមានកម្រិតខ្លះពីគំរូនៃសេដ្ឋកិច្ចវិទ្យាក៏ដោយ ក៏លទ្ធផលនៃការវិភាគបង្ហាញថា ទឹកប្រាក់នៃការវិនិយោគសរុបចំនួន៤៧ ១៧១,៨ពាន់លានរៀល (១១,៥០៥ពាន់លានដុល្លារអាមេរិក) គឺជាតម្រូវការដើម្បីសម្រេចបាននូវកំណើន *ផសស* ដែលបានគ្រោងទុកសម្រាប់ដំណាក់កាលនៃ *កវស បីឆ្នាំរំកិល២០១២-២០១៤*។

២០. ប្រភពផ្តល់ហិរញ្ញប្បទានដល់វិនិយោគសរុបចំនួន៤៧ ១៧១,៨ពាន់លានរៀល ក្នុងអំឡុងពេល *កវស បីឆ្នាំរំកិល២០១២-២០១៤* (មានបង្ហាញនៅក្នុងតារាងទី៣)៖

- វិនិយោគមូលធនរបស់វិស័យឯកជននឹងមានប្រមាណ៣១ ៧១៣,៩ពាន់លានរៀល (៧,៧៣៥ពាន់លានដុល្លារអាមេរិក) សមមូលនឹង៦៧,៣ភាគរយនៃវិនិយោគមូលធនសរុប។
- វិនិយោគមូលធនវិស័យសាធារណៈនឹងមានប្រមាណ១៥ ៤៥៨ពាន់លានរៀល (៣,៧៧០ពាន់លានដុល្លារអាមេរិក) សមមូលនឹង៣២,៧ភាគរយនៃវិនិយោគមូលធនសរុប។

២១. ប្រភពធនធានសម្រាប់តម្រូវការវិនិយោគពីក្នុងស្រុកនិងពីក្រៅប្រទេសសម្រាប់ផ្តល់ហិរញ្ញប្បទានដល់តម្រូវការវិនិយោគសរុប៤៧ ១៧១,៨ពាន់លានរៀល ក្នុងអំឡុងពេល *កវស បីឆ្នាំរំកិល២០១២-២០១៤*៖

- ២៦ ២៣៩ពាន់លានរៀល(៦,៣៩៩ពាន់លានដុល្លារអាមេរិក) សមមូលនឹង៥៥,៦ ភាគរយនៃវិនិយោគមូលធនសរុប នឹងត្រូវបានទទួលពីប្រភពក្នុងស្រុក។
- ២០ ៩៣៣ពាន់លានរៀល(៥,១០៥ពាន់លានដុល្លារអាមេរិក) សមមូលនឹង៤៤,៤ ភាគរយនៃវិនិយោគមូលធនសរុប នឹងត្រូវបានទទួលពីប្រភពក្រៅប្រទេស។

## តារាងទី៣ ការវិនិយោគចាំបាច់ដើម្បីសម្រេចបានកំណើន ផសស ដែលបានគ្រោងទុក និងធនធានដែលអាចមានសម្រាប់ធ្វើហិរញ្ញប្បទានដល់ការវិនិយោគចាំបាច់

*(គិតជាពាន់លានរៀល)*

| ប្រភពហិរញ្ញប្បទាន | ២០១១ | ២០១២ | ២០១៣ | ២០១៤ | សរុប ២០១២ -២០១៤ |
|---|---|---|---|---|---|
| **វិនិយោគមូលធនសរុប** | **១២ ៨៩៥,១** | **១៤ ១១២,៥** | **១៥ ៧៤០,៥** | **១៧ ៣១៨,៨** | **៤៧ ១៧១,៨** |
| • **វិនិយោគមូលធនវិស័យសាធារណៈ** | **៤ ២៧៧,៦** | **៤ ៦៦១,៧** | **៥ ១៣៩,៥** | **៥ ៦៦០,៧** | **១៥ ៤៩៧,៩** |
| • ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ១ ១៤៤,0 | ១ ២៤៦,៧ | ១ ៣៧៣,៤ | ១ ៥១៣,៨ | ៤ ១៣៣,៩ |
| • ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស[១] | ៣ ១៣៣,៦ | ៣ ៤១៥,១ | ៣ ៧៦២,១ | ៤ ១៤៦,៩ | ១១ ៣២៤,0 |
| • **វិនិយោគមូលធនវិស័យឯកជន** | **៨ ៥៧៧,៥** | **៩ ៤៥0,៨** | **១0 ៦0៥,0** | **១១ ៦៥៨,១** | **៣១ ៧១៣,៩** |
| • ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ៥ ៩៩១,៦ | ៦ ៥៨៤,៣ | ៧ ៤0៣,៩ | ៨ ១១៦,៩ | ២២ ១0៥,១ |
| • ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស | ២ ៥៨៥,៩ | ២ ៨៦៦,៥ | ៣ ២0១,១ | ៣ ៥៤១,៣ | ៩ ៦0៨,៨ |
| **វិនិយោគមូលធនសរុប** | **១២ ៨៩៥,១** | **១៤ ១១២,៥** | **១៥ ៧៤០,៥** | **១៧ ៣១៨,៨** | **៤៧ ១៧១,៨** |
| • វិនិយោគមូលធនរបស់វិស័យសាធារណៈ | **៤ ២៧៧,៦** | **៤ ៦៦១,៧** | **៥ ១៣៩,៥** | **៥ ៦៦០,៧** | **១៥ ៤៩៧,៩** |
| • វិនិយោគមូលធនរបស់វិស័យឯកជន | **៨ ៥៧៧,៥** | **៩ ៤៥0,៨** | **១0 ៦0៥,0** | **១១ ៦៥៨,១** | **៣១ ៧១៣,៩** |
| **វិនិយោគមូលធនសរុប** | **១២ ៨៩៥,១** | **១៤ ១១២,៥** | **១៥ ៧៤០,៥** | **១៧ ៣១៨,៨** | **៤៧ ១៧១,៨** |
| • ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ៧ ១៣៥,៦ | ៧ ៨៣១,0 | ៨ ៧៧៧,៣ | ៩ ៦៣0,៧ | ២៦ ២៣៩,0 |
| • ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស | ៥ ៧១៩,៥ | ៦ ២៨១,៦ | ៦ ៩៦៣,២ | ៧ ៦៨៨,២ | ២0 ៩៣២,៨ |
| • **វិនិយោគមូលធនវិស័យសាធារណៈ** | **៤ ២៧៧,៦** | **៤ ៦៦១,៧** | **៥ ១៣៩,៥** | **៥ ៦៦០,៧** | **១៥ ៤៩៧,៩** |
| • ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ១ ១៤៤,0 | ១ ២៤៦,៧ | ១ ៣៧៣,៤ | ១ ៥១៣,៨ | ៤ ១៣៣,៩ |
| • ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស[២] | ៣ ១៣៣,៦ | ៣ ៤១៥,១ | ៣ ៧៦២,១ | ៤ ១៤៦,៩ | ១១ ៣២៤,0 |

[១] មានមូលដ្ឋានលើអត្រាប្តូរប្រាក់៤១00រៀល = ១ដុល្លារអាមេរិក

[២] វិនិយោគជាទុន មិនរាប់បញ្ចូលបច្ចេកទេស

*__ប្រភព__ : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

២២. ការបែងចែកលម្អិតនៃការវិនិយោគចាំបាច់ដើម្បីសម្រេចបានកំណើន ផសស សរុប ដែលបានគ្រោងទុកតាមរយៈវិស័យសេដ្ឋកិច្ច ត្រូវបានបង្ហាញក្នុងតារាងទី៤។ ដើម្បីសម្រេចបានអត្រាកំណើន ផសស សរុប ដែលបានគ្រោងទុកតាមវិស័យ ការវិនិយោគក្នុងក្រុមវិស័យសំខាន់ៗ រួមមានដូចខាងក្រោម៖

- វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវការទុនវិនិយោគចំនួន៧ ២៦៥,៧ពាន់លានរៀល(១,៧៧ពាន់លានដុល្លារអាមេរិក) ដែលផ្តោតជាសំខាន់លើដំណាំស្រូវ ជាពិសេសដើម្បីអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់ការបង្កើនការនាំអង្ករទៅទីផ្សារអន្តរជាតិសម្រាប់រយៈពេល *កវស បីឆ្នាំរំកិល២០១២-២០១៤*។

០ វិស័យឧស្សាហកម្មទូទៅ រួមមានការរុករករ៉ែ កម្មន្តសាល អគ្គិសនី ឧស្ម័ន ទឹក និងសំណង់ នឹងត្រូវការទុនវិនិយោគចំនួន២៣ ០៣១,១ពាន់លានរៀល( ៥,៦ពាន់លានដុល្លារអាមេរិក) សម្រាប់រយៈពេល *កវស បីឆ្នាំរំកិល២០១២-២០១៤* ។ នៅក្នុងក្រុមនេះ អនុវិស័យកម្មន្តសាល(វាយនភណ្ឌ សម្លៀកបំពាក់ និងស្បែកជើង) នឹងត្រូវការចំណែកធំជាងគេនៃការវិនិយោគ គឺមានចំនួនប្រមាណ៨ ៩៥២,៩ពាន់លានរៀល(២,១៨៣ពាន់លានដុល្លារអាមេរិក) និងអនុវិស័យសំណង់ ត្រូវការចំណែកធំនៃការវិនិយោគ គឺមានចំនួន៩ ៣៦៣,៦ពាន់លានរៀល(២,២៨៣ពាន់លានដុល្លារអាមេរិក) ហើយអនុវិស័យអគ្គិសនី ឧស្ម័ន និងទឹក ត្រូវការទុនវិនិយោគចំនួនប្រមាណ៣ ៥៥០ពាន់លានរៀល(០,៨៦៦ពាន់លានដុល្លារអាមេរិក) ។

០ វិស័យសេវាកម្មរួមមាន ពាណិជ្ជកម្ម សណ្ឋាគារ និងភោជនីយដ្ឋាន(ទេសចរណ៍) ដឹកជញ្ជូន និងទូរគមនាគមន៍ ហិរញ្ញវត្ថុ រដ្ឋបាលសាធារណៈ និងអចលនទ្រព្យ ត្រូវការទុនវិនិយោគ ១៦ ៨៧៤,៩ពាន់លានរៀល(៤,១១៥ពាន់លានដុល្លារអាមេរិក)។

**តារាងទី៤ វិនិយោគមូលធនដែលត្រូវការតាមវិស័យនីមួយៗដើម្បីសម្រេចបានគោលដៅនៃកំណើន ផសស**

*(គិតជាពាន់លានរៀល)*

| | ២០១១ | ២០១២ | ២០១៣ | ២០១៤ | សរុប ២០១២ -២០១៤ |
|---|---|---|---|---|---|
| **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **១ ៩៧២,២** | **២ ២៦០,៦** | **២ ៤១៩,០** | **២ ៥៨៦,១** | **៧ ២៦៥,៧** |
| ដំណាំ | ១ ៥៨៥,៨ | ១ ៧៩២,១ | ១ ៩២៣,៥ | ២ ០៦២,០ | ៥ ៧៧៧,៧ |
| ចិញ្ចឹមសត្វ | ១១៥,១ | ១៤៤,៦ | ១៥៦,១ | ១៦៨,៦ | ៤៦៩,៣ |
| នេសាទ | ១៤៩,៨ | ១៨៦,៦ | ១៩៦,៧ | ២០៧,១ | ៥៩០,៤ |
| ព្រៃឈើ | ១២១,៥ | ១៣៧,៣ | ១៤២,៧ | ១៤៨,៣ | ៤២៨,២ |
| **ឧស្សាហកម្ម** | **៦ ០០៦,២** | **៦ ៨៥២,៨** | **៧ ៦៥០,៥** | **៨ ៥២៧,៨** | **២៣ ០៣១,១** |
| រ៉ែ | ៣១០,២ | ៣៤៦,៣ | ៣៨៦,៦ | ៤៣១,៧ | ១ ១៦៤,៦ |
| ផលិតកម្ម | ២ ៤២៩,៩ | ២ ៦៩០,៩ | ២ ៩៧៨,៨ | ៣ ២៨៣,៣ | ៨ ៩៥២,៩ |
| -អាហារ ភេសជ្ជៈ និងថ្នាំជក់ | ២៣៧,៣ | ២៥៧,០ | ២៧៨,២ | ៣០១,៣ | ៨៣៦,៥ |
| -វាយនភណ្ឌ | ៩៨៣,១ | ១ ១១៨,៨ | ១ ២៦៥,១ | ១ ៤១៥,០ | ៣ ៧៩៨,៩ |
| -ឈើ ក្រដាស និងផ្នែកបោះពុម្ព | ៦៩,៨ | ៧៤,២ | ៧៨,៩ | ៨៣,៨ | ២៣៦,៩ |
| -ផលិតកម្មជ័រកៅស៊ូ | ៨១,៧ | ៩២,០ | ១០៣,៧ | ១១៦,៨ | ៣១២,៦ |
| -ផលិតកម្មដទៃ | ១ ០៥៨,០ | ១ ១៤៨,៨ | ១ ២៥២,៩ | ១ ៣៦៦,៣ | ៣ ៧៦៨,០ |
| អគ្គិសនី ឧស្ម័ន និងទឹកស្អាត | ៩១៧,១ | ១ ០៦៨,៣ | ១ ១៧៩,៥ | ១ ៣០២,២ | ៣ ៥៥០,០ |
| សំណង់ | ២ ៣៤៨,៩ | ២ ៧៤៧,៣ | ៣ ១០៥,៦ | ៣ ៥១០,៧ | ៩ ៣៦៣,៦ |

| សេវាកម្ម | ៤ ៨៧៦,៧ | ៤ ៩៩៩,០ | ៥ ៦៧០,០ | ៦ ២០៥,០ | ១៦ ៨៧៤,៩ |
|---|---|---|---|---|---|
| ពាណិជ្ជកម្ម | ៨៦៥,១ | ៩៤៣,៧ | ១ ០២៩,៤ | ១ ១២២,៨ | ៣ ០៩៥,៩ |
| សណ្ឋាគារនិងភោជនីយដ្ឋាន | ៦៣៧,០ | ៧១២,៨ | ៧៩៧,៧ | ៨៩០,៨ | ២ ៤០១,៣ |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | ៨៥៧,១ | ៩៤២,១ | ១ ០២២,៩ | ១ ១១០,៧ | ៣ ០៧៥,៨ |
| ហិរញ្ញវត្ថុ | ១២៥,៦ | ១៤០,៧ | ១៥៦,៨ | ១៧៤,៧ | ៤៧២,២ |
| រដ្ឋបាលសាធារណៈ | ១ ១៩៧,៧ | ៩៦០,៩ | ១ ០២៤,៦ | ១ ០៩២,៦ | ៣ ០៧៨,២ |
| អចលនទ្រព្យនិងធុរកិច្ច | ៧២៧,៥ | ៧៨៩,៦ | ៨៧៦,៩ | ៩៧៣,៣ | ២ ៦៣៩,៨ |
| សេវាកម្មដទៃទៀត | ៤៦៦,៦ | ៥០៩,២ | ៧៦២,៦ | ៨៤០,១ | ២ ១១១,៨ |
| **សរុប** | **១២ ៨៥៥,១** | **១៤ ១១២,៥** | **១៥ ៧៤០,៥** | **១៧ ៣១៨,៨** | **៤៧ ១៧១,៨** |

*ប្រភព ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

## ៤. ចំណូលនិងចំណាយថវិកា២០១២-២០១៤

២៣. ដោយសារវិបត្តិហិរញ្ញវត្ថុសកលលោកនិងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចសកលលោកដែលបានកើតឡើងក្នុងប្រទេសអភិវឌ្ឍបានជះឥទ្ធិពលអវិជ្ជមានមកលើសេដ្ឋកិច្ចកម្ពុជា ចំណូលថវិកាបានធ្លាក់ចុះពី១៣,៣ភាគរយនៃ ផសស សរុប ក្នុងឆ្នាំ២០០៨ មក១១,៩ភាគរយនៃ ផសស សរុប ក្នុងឆ្នាំ២០០៩។ ចំណូលថវិកាត្រូវបានព្យាករថានឹងកើនឡើងវិញជាបន្តបន្ទាប់ហើយនឹងកើនលើសកម្រិតក្នុងឆ្នាំ២០០៨ នៅឆ្នាំ២០១១ ហើយត្រូវបានព្យាករថានឹងកើនដល់១៤,៨ភាគរយនៃ ផសស សរុប ក្នុងឆ្នាំ២០១៤។ ការអនុវត្តវិធានការនានារបស់រាជរដ្ឋាភិបាល ដែលផ្តោតលើការការពារក្រុមជនងាយរងគ្រោះ និងប្រជាជនក្រីក្រពីផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុសកលលោកនិងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចសកលលោក ក៏ដូចជាការអនុវត្តវិធានការសម្រាប់ជំរុញតម្រូវការតាមរយៈកញ្ចប់គោលនយោបាយសម្រាប់ជំរុញកំណើន ជាពិសេសការផ្តល់ការឧបត្ថម្ភដល់កម្មករកាត់ដេរដែលបាត់បង់ការងារ បានធ្វើឲ្យចំណាយថវិកាជាសមាមាត្រនៃ ផសស សរុប បានកើនឡើងពី១៥,៩ភាគរយក្នុងឆ្នាំ២០០៨ ដល់២០,៥ភាគរយក្នុងឆ្នាំ២០០៩ និងដល់២០,៧ភាគរយក្នុងឆ្នាំ២០១០។ កម្រិតនៃការចំណាយនេះនឹងរក្សាបាននៅត្រឹម១៩ទៅ២០ភាគរយនៅឆ្នាំ២០១៤តាមរយៈនៃកិច្ចខិតខំប្រឹងប្រែងប្រមូលចំណូលបន្ថែមទៀត និងអាចរក្សាបាននូវឱនភាពថវិកាក្នុងកម្រិត២ទៅ៣ភាគរយ។

២៤. ជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាននិងកំពុងអនុវត្តដំណើរការចំនួនពីរ ដើម្បីផ្តល់ជាធាតុចូលក្នុងការរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ។ ទីមួយ គឺ *ក្របខ័ណ្ឌចំណាយសម្រាប់រយៈមធ្យម* ដែលព្យាករពីតួលេខចំណាយចរន្តសម្រាប់រយៈពេលបីឆ្នាំខាងមុខ។ ការព្យាករនេះនឹងត្រូវធ្វើបច្ចុប្បន្នកម្មរៀងរាល់ឆ្នាំ។ ការព្យាករផ្អែកលើការវិភាគម៉ាក្រូសេដ្ឋកិច្ចពីលើចុះក្រោម ដោយមើលលើការអនុវត្តនៃសេដ្ឋកិច្ចគោលនយោបាយអាទិភាព ក៏ដូចជាព័ត៌មានបានពីស្ថាប័ននានារបស់រាជរដ្ឋាភិបាល។ ទីពីរ គឺ

*ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃថវិកាសម្រាប់រយៈពេលបីឆ្នាំ* ដែលអនុវត្តតាមអភិក្រមពីក្រោមទៅលើ។ ធាតុចូលដែលសម្រាប់យកមកប្រើប្រាស់ក្នុងការវិភាគនេះ ផ្អែកលើព័ត៌មានដែលប្រមូលបានពីការផ្លាស់ប្តូរយោបល់រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័ននានារបស់រាជរដ្ឋាភិបាល និងព័ត៌មានស្តីពីចំណាយនិងតម្រូវការរយៈពេលពីរឆ្នាំទៅមុខនៃស្ថាប័នទាំងនោះ។ ក្នុងការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងបន្តពង្រឹងភាពផ្សារភ្ជាប់គ្នានៃដំណើរការទាំងពីរ ដើម្បីកែលម្អការរៀបចំថវិកាប្រចាំឆ្នាំ។

## ៥. ចំណុចដៅនៃការកៀរគរធនធាន សម្រាប់ការវិនិយោគរបស់វិស័យសាធារណៈ ឆ្នាំ២០១២-២០១៤

២៥. រាជរដ្ឋាភិបាលបានកំណត់ចំណុចដៅនៃតម្រូវការវិនិយោគរបស់វិស័យសាធារណៈដែលអាចមានតម្លៃប្រមាណ២៥ ៧៤០,៦ពាន់លានរៀល(៦,៣ពាន់លានដុល្លារអាមេរិក) ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៤នៃរដ្ឋសភា។ តម្លៃប៉ាន់ស្មាននេះ រួមបញ្ចូលនូវៈ *(១)* តម្រូវការវិនិយោគមូលធនសម្រាប់វិស័យសាធារណៈដែលអាចមានប្រមាណ១៧ ៥៤០,៦ពាន់លានរៀល(៤,២៧៨ពាន់លានដុល្លារអាមេរិក) *(២)* ធនធានដែលត្រូវការជាចាំបាច់ដើម្បីផ្តល់ការគាំទ្រដែលមានគោលដៅច្បាស់លាស់ដល់ការអភិវឌ្ឍ ការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទសំដៅកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទនិងតំបន់ដាច់ស្រយាល និងការផ្តល់ការគាំទ្របន្ទាន់ដល់ការសម្រាលផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុសកលលោក និងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចសកលលោកទៅលើប្រជាជនក្រីក្រនិងប្រជាជនងាយរងគ្រោះ ដែលអាចមានប្រមាណ៤ ១០០ពាន់លានរៀល(១ពាន់លានដុល្លារអាមេរិក) *(៣)* ធនធានដែលត្រូវការជាចាំបាច់ដើម្បីពង្រីកសេវាសង្គមកិច្ចសំដៅឈានទៅសម្រេចបាននូវចំណុចដៅទាំងឡាយនៃ *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* ដែលអាចមានប្រមាណ២ ០៥០ពាន់លានរៀល(០,៥ពាន់លានដុល្លារអាមេរិក) និង *(៤)* ធនធានដែលត្រូវការជាចាំបាច់ដើម្បីពង្រឹងសមត្ថភាពស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតកម្មវិធីនិងការផ្តល់នូវសេវាកម្មប្រកបដោយប្រសិទ្ធភាពដែលអាចមានប្រមាណ២ ០៥០ពាន់លានរៀល(០,៥ពាន់លានដុល្លារអាមេរិក)។

**តារាងទី៥ ចំណុចដៅនៃការគៀរគរធនធានសម្រាប់វិនិយោគរបស់វិស័យសាធារណៈ ឆ្នាំ២០១២-២០១៤**

| តម្រូវការវិនិយោគវិស័យសាធារណៈ | ២០១២-២០១៤ | |
|---|---|---|
| | ពាន់លានរៀល | លានដុល្លារអាមេរិក |
| ១. វិនិយោគមូលធនរបស់វិស័យសាធារណៈ (ការព្យាករម៉ាក្រូសេដ្ឋកិច្ច) | ១៥ ៤៥៧,៩ | ៣ ៧៧០,២ |
| ២. ការគាំទ្រដែលមានគោលដៅច្បាស់លាស់ដល់ការអភិវឌ្ឍនិងពិពិធកម្មសេដ្ឋកិច្ចជនបទដើម្បីកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទនិងតំបន់ដាច់ស្រយាលនិងដើម្បីសម្រាលផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុសកលលោកនិងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចសកលលោកដែលមានផលប៉ះពាល់ទៅលើក្រុមជនងាយរងគ្រោះនិងប្រជាជនក្រីក្រ | ២ ៥០១,០ | ៦១០,០ |
| ៣. ការពង្រីកសេវាសង្គមកិច្ចដើម្បីឈានទៅសម្រេចបាននូវចំណុចដៅទាំងឡាយនៃ *គអសក* | ១ ២៥១,០ | ៣០៥,១ |
| ៤. ការគាំទ្រដល់ការពង្រឹងសមត្ថភាពនៃស្ថាប័នរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ក្នុងការបង្កើតកម្មវិធីនិងការផ្តល់នូវសេវាកម្ម ប្រកបដោយប្រសិទ្ធភាព | ១ ២៥២,០ | ៣០៥,៤ |
| ***សរុប*** | ***២០ ៤៦១,៩*** | ***៤ ៩៩០,៧*** |

២៦. សម្រាប់ *កវស បីឆ្នាំរំកិល២០១២-២០១៤* គឺត្រូវការថវិកាសរុបប្រមាណ១៥ ៤៥៧,៩ ពាន់លានរៀល(៣ ៧៧០លានដុល្លារអាមេរិក)ឬប្រមាណ៥ ១៥២,៩ពាន់លានរៀល (១ ២៥៦លានដុល្លារអាមេរិក)ក្នុងមួយឆ្នាំដូចមានបង្ហាញនៅតារាងទី៣។ បរិមាណតម្រូវការថវិកាសរុបសម្រាប់ *កវស បីឆ្នាំរំកិល២០១២-២០១៤*នេះ គឺមានការកើនឡើងខ្ពស់ជាងការវិភាជនៅក្នុង *ផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣*។ បរិមាណថវិកាសរុបសម្រាប់អនុវត្ត *កវស បីឆ្នាំរំកិល២០១២-២០១៤* ប្រមាណ១៥ ៤៥៧,៩ពាន់លានរៀល(៣ ៧៧០លាន ដុល្លារអាមេរិក) ដែលក្នុងនោះ ហិរញ្ញប្បទានក្នុងស្រុកដោយរាជរដ្ឋាភិបាលមាន៤ ១៣៣,៩ពាន់លានរៀល (១ ០០៨,៩លានដុល្លារអាមេរិក) និងចំណែកដែលនៅសល់១១ ៣២៤,០ពាន់លានរៀល (២ ៧៦២,០លានដុល្លារអាមេរិក)ឬប្រមាណ៣ ៧៧៤,៦ពាន់លានរៀល(៩២០,៦លាន ដុល្លារអាមេរិក) ក្នុងមួយឆ្នាំ អាចត្រូវបានធ្វើហិរញ្ញប្បទានពីប្រភពដូចខាងក្រោម៖

- o ហិរញ្ញប្បទានឥតសំណងពីដៃគូអភិវឌ្ឍក្រៅប្រទេសជាប្រពៃណី(ភាគច្រើនពីដៃគូអភិវឌ្ឍទ្វេភាគី ពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាល)។
- o កម្ចីសម្បទានពីដៃគូអភិវឌ្ឍក្រៅប្រទេស(ភាគច្រើនពីស្ថាប័នហិរញ្ញវត្ថុពហុភាគីនិងទ្វេភាគីសំខាន់ៗ)។
- o ធនធានពីប្រភពដៃគូអភិវឌ្ឍមិនមែនប្រពៃណី(ហិរញ្ញប្បទានឥតសំណងនិងកម្ចីពាក់កណ្តាលសម្បទាន)។
- o ចំណូលថ្មីៗដែលអាចបានមកពីការអភិវឌ្ឍឧស្សាហកម្មអាជីវកម្មរ៉ែ(ប្រេង ឧស្ម័ន និងធនធានរ៉ែ) នៅពេលដែលអាជីវកម្មនេះត្រូវបានដំណើរការជាលក្ខណៈពាណិជ្ជកម្ម។

២៧. រាជរដ្ឋាភិបាលកម្ពុជាមានជំនឿជឿជាក់ថា តម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈដែលមានប្រមាណ១១ ៣២៤,០ពាន់លានរៀល(២ ៧៦២,០លានដុល្លារអាមេរិក)ឬប្រមាណ

៣ ៧៧៤,៦ពាន់លានរៀល(៩២០,៦លានដុល្លារអាមេរិក)ក្នុងមួយឆ្នាំ អាចនឹងទទួលបានពីការបន្តគាំទ្រពីដៃគូអភិវឌ្ឍជាប្រពៃណីនិងមិនមែនជាប្រពៃណី និងពីចំណូលបន្ថែមថ្មី ពីប្រេងឧស្ម័ន និងធនធានរ៉ែ នៅពេលដែលអាជីវកម្មនេះត្រូវបានដំណើរការជាលក្ខណៈពាណិជ្ជកម្ម។ ក៏ប៉ុន្តែ ការកៀរគរហិរញ្ញប្បទានបន្ថែមពីដៃគូ ដូចជាមិនបានបង្ហាញពីភាពងាយស្រួលនោះឡើយ ដោយសារដៃគូភាគច្រើនបានសន្យាផ្តល់រួចមកហើយ និងដើម្បីសម្រេចបានហិរញ្ញប្បទានគ្រប់ចំនួន គឺត្រូវខិតខំស្វែងរកបន្ថែមទៀតនូវដៃគូថ្មីផ្សេងៗទៀត។ សម្រាប់រាជរដ្ឋាភិបាល គឺត្រូវពិនិត្យឲ្យច្បាស់លាស់នូវកំណែទម្រង់សេដ្ឋកិច្ច ដូចជា ការបង្កើនទិន្នផលស្រូវនិងការនាំចេញ និងការធ្វើពិពិធកម្មដំណាំផ្សេងៗក្រៅពីដំណាំស្រូវ ជាពិសេស សម្រាប់អនាគត ត្រូវគ្រប់គ្រងចំណូលទទួលបានពីអាជីវកម្មរ៉ែ ដីសម្បទាន និងចំណូលពន្ធ។

២៨. វិភាជន៍តាមវិស័យនិងអនុវិស័យនៃតម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈ សម្រាប់ឆ្នាំ ២០១២-២០១៤ នៅក្នុងតារាងទី៦ខាងក្រោម គឺមានមូលដ្ឋានពីការវិភាជតាមវិស័យនិងអនុវិស័យ ចែងនៅក្នុងតារាងទី២៦ នៃ *ផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣*។

**តារាងទី៦ វិភាជន៍តាមវិស័យនិងអនុវិស័យសម្រាប់តម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈ ដោយមានមូលដ្ឋានពីការវិភាជតាមវិស័យនិងអនុវិស័យ ចែងនៅក្នុង ផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣**

| វិស័យ | បរិមាណវិភាជន៍ ២០១២-២០១៤[1] | | ភាគរយ | ជនបទ | ភាគរយ | ទីប្រជុំជន | ភាគរយ |
|---|---|---|---|---|---|---|---|
| | ពាន់លានរៀល | លានដុល្លារអាមេរិក | | | | | |
| **វិស័យសង្គមកិច្ច** | | | | | | | |
| អប់រំ : ក្នុងនោះ ការអប់រំមូលដ្ឋាន៦០% | ១ ៨៥៩,៩ | ៤៥២,៤ | ១២,០ | ១ ១១៣,០ | ៦០,០ | ៧៤២,០ | ៤០,០ |
| បច្ចេកទេសនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៦១៨,៣ | ១៥០,៨ | ៤,០ | ៣០៩,២ | ៥០,០ | ៣០៩,២ | ៥០,០ |
| សុខាភិបាល៤០% | ១ ៨៥៤,៩ | ៤៥២,៤ | ១២,០ | ១ ២៩៨,៥ | ៧០,០ | ៥៥៦,៥ | ៣០,០ |
| កម្មវិធីដើម្បីជួយកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីវិបត្តិហិរញ្ញវត្ថុពិភពលោកលើជនងាយរងគ្រោះនិងអ្នកក្រ | ៦១៨,៣ | ១៥០,៨ | ៤,០ | ៤៩៤,៧ | ៨០,០ | ១២៣,៧ | ២០,០ |
| **សរុប** | **៤ ៩៤៦,៥** | **១ ២០៦,៥** | **៣២,០** | **៣ ២១៥,២** | **៦៥,០** | **១ ៧៣១,៣** | **៣៥,៥** |
| **វិស័យសេដ្ឋកិច្ច** | | | | | | | |
| កសិកម្មនិងការគ្រប់គ្រងដីធ្លី : ក្រៅពីដំណាំ | ៦១៨,៣ | ១៥០,៨ | ៤,០ | ៥៨៧,៤ | ៩៥,០ | ៣០,៩០ | ៥,០ |
| ដំណាំតាមរដូវ : ស្រូវនិងផ្សេងៗ | ៦១៨,៣ | ១៥០,៨ | ៤,០ | ៦១៨,៣ | ១០០ | ០,០ | ០,០ |
| អភិវឌ្ឍន៏ជនបទ | ១ ៨៥៤,៩ | ៤៥២,៤ | ១២,០ | ១ ៨៥៤,៩ | ១០០ | ០,០ | ០,០ |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | ៦១៨,៣ | ១៥០,៨ | ៤,០ | ២៤៧,៣ | ៤០,០ | ៣៧១,០០ | ៦០,០ |
| **សរុប** | **៣ ៧០៩,៩** | **៩០៤,៨** | **២៤,០** | **៣ ៣០៩,២០** | **៨៩,២** | **៤០១,៩** | **១០,៨** |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **ហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | |
| ដឹកជញ្ជូន ( ផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក អាកាសចរណ៍) | ១ ៨៥៤,៩ | ៤៥២,៤ | ១២,០ | ៩២៧,៥ | ៥០,០ | ៩២៧,៥ | ៥០,០ |
| ទឹកនិងអនាម័យ( មិនគិតនៅជនបទ) | ៦១៨,៣ | ១៥០,៨ | ៤,០ | ១៥៤,៦ | ២៥,០ | ៤៦៣,៧ | ៧៥,០ |
| ថាមពលនិងអគ្គិសនី | ៦១៨,៣ | ១៥០,៨ | ៤,០ | ៣០៩,២ | ៥០,០ | ៣០៩,២ | ៥០,០ |
| ប្រៃសណីយ៍និងទូរគមនាគមន៍ | ១៥៤,៦ | ៣៧,៧ | ១,០ | ៧៧,៣ | ៥០,០ | ៧៧,៣ | ៥០,០ |
| **សរុប** | **៣ ២៤៦,២** | **៧៩១,៧** | **២១,០** | **១ ៤៦៧,២** | **៤៥,២** | **១ ៧៧៨,៩** | **៥៤,៨** |
| **សេវាកម្មនិងកម្មវិធីអន្តរវិស័យ** | | | | | | | |
| ការបញ្ច្រាបយេនឌ័រ | ២៣១,៩ | ៥៦,៦ | ១,៥ | ៦៩,៦ | ៣០,០ | ១៦២,៣ | ៧០,០ |
| ទេសចរណ៍ | ៣០៩,២ | ៧៥,៤ | ២,០ | ៧៧,៣ | ២៥,០ | ២៣១,៩ | ៧៥,០ |
| បរិស្ថាននិងការអភិរក្ស | ៦១៨,៣ | ១៥០,៨ | ៤,០ | ៥៥៦,៥ | ៩០,០ | ៦១,៨ | ១០,០ |
| សហគមន៍និងសេវាកម្មសង្គម | ៦១៨,៣ | ១៥០,៨ | ៤,០ | ៤៦៣,៧ | ៧៥,០ | ១៥៤,៦ | ២៥,០ |
| វប្បធម៌និងសិល្បៈ | ២៣១,៩ | ៥៦,៦ | ១,៥ | ១១៥,៩ | ៥០,០ | ១១៥,៩ | ៥០,០ |
| អភិបាលកិច្ចនិងរដ្ឋបាល | ១ ២៣៦,៦ | ៣០១,៦ | ៨,០ | ៤៩៤,៧ | ៤០,០ | ៧៤២,០ | ៦០,០ |
| **សរុប** | **៣ ២៤៦,២** | **៧៩១,៧** | **២១,០** | **១ ៧៧៨,៧** | **៥៤,៨** | **១ ៤៦៧,៣** | **៤៥,២** |
| មិនទាន់បែងចែក | ៣០៩,២ | ៧៥,៤ | ២,០ | ១៥៤,៦ | ៥០,០ | ១៥៤,៦ | ៥០,០ |
| **សរុបរួម** | **១៥ ៤៥៧,៩** | **៣៧៧០,២** | **១០០,០** | **៩ ៩២៣,២** | **៦៤,២** | **៥ ៥៣៣,៨** | **៣៥,៨** |

[១] *បង្ហាញពាភាគ៥នៃវិភាជន៍តម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈសរុបសម្រាប់ឆ្នាំ ២០០៩-២០១៣*

# ជំពូកទី៣

## កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល២០១២-២០១៤

២៩. ដូចបានបង្ហាញក្នុងជំពូកមុនដែរ សម្រាប់ការអនុវត្ត *ផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣* (រយៈពេលប្រាំឆ្នាំ) រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការប៉ាន់ស្មានតម្លៃសរុបចំនួន២៥ ៧៤០,៦ពាន់លានរៀល(៦ ២៧៨,១លានដុល្លារអាមេរិក)សម្រាប់បំពេញតម្រូវការវិនិយោគវិស័យសាធារណៈ ដើម្បីឈានទៅសម្រេចបានការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល នីតិកាលទី៤។ ការវិភាជសម្រាប់ *កវស បីឆ្នាំរំកិល២០១២-២០១៤* មានចំនួន១៥ ៤៥៧,៩ពាន់លានរៀល(៣ ៧៧០,២លានដុល្លារអាមេរិក) (តារាងទី៧) និងដូចមានចែងនៅក្នុងក្របខ័ណ្ឌចំណាយសម្រាប់រយៈពេលមធ្យម គឺរាជរដ្ឋាភិបាលកម្ពុជាបានវិភាជថវិកាជាតិ ចំនួន៤ ១៣៣,៩ ពាន់លានរៀល (១ ០០៨,២លានដុល្លារអាមេរិក) សម្រាប់ *កវស បីឆ្នាំរំកិល២០១២-២០១៤*។

**តារាងទី៧ វិភាជន៍តាមវិស័យនិងអនុវិស័យ សម្រាប់តម្រូវការវិនិយោគវិស័យសាធារណៈ ចែងនៅក្នុង ផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣ និង កវស បីឆ្នាំរំកិល២០១២-២០១៤**

| វិស័យនិងអនុវិស័យ | គោលដៅវិនិយោគសាធារណៈក្នុង ផយអជ បច្ចុប្បន្នកម្ម | | | | | |
|---|---|---|---|---|---|---|
| | ផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣ | | | កវស ២០១២-២០១៤ | | |
| | ពាន់លានរៀល | លានដុល្លារអាមេរិក | ភាគរយ | ពាន់លានរៀល | លានដុល្លារអាមេរិក | ភាគរយ |
| **វិស័យសង្គមកិច្ច** | | | | | | |
| អប់រំ : (ក្នុងនោះ ការអប់រំមូលដ្ឋាន៦០%) | ៣ ០៨៨,៩ | ៧៥៣,៤ | ១២,០ | ១ ៨៥៤,៩ | ៤៥២,៤ | ១២,០ |
| បច្ចេកទេសនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១ ០២៩,៦ | ២៥១,១ | ៤,០ | ៦១៨,៣ | ១៥០,៨ | ៤,០ |
| សុខាភិបាល | ៣ ០៨៨,៩ | ៧៥៣,៤ | ១២,០ | ១ ៨៥៤,៩ | ៤៥២,៤ | ១២,០ |
| កម្មវិធីដើម្បីជួយកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីវិបត្តិហិរញ្ញវត្ថុពិភពលោកលើជនងាយរងគ្រោះនិងអ្នកក្រ | ១ ០២៩,៦ | ២៥១,១ | ៤,០ | ៦១៨,៣ | ១៥០,៨ | ៤,០ |
| **សរុប** | **៨ ២៣៧,០** | **២ ០០៩,០** | **៣២,០** | **៤ ៩៤៦,៥** | **១ ២០៥,៤** | **៣២,០** |
| **វិស័យសេដ្ឋកិច្ច** | | | | | | |
| កសិកម្មនិងការគ្រប់គ្រងដីធ្លី : ក្រៅពីដំណាំ | ១ ០២៩,៦ | ២៥១,១ | ៤,០ | ៦១៨,៣ | ១៥០,៨ | ៤,០ |
| ដំណាំតាមរដូវ : ស្រូវនិងផ្សេងៗ | ១ ០២៩,៦ | ២៥១,១ | ៤,០ | ៦១៨,៣ | ១៥០,៨ | ៤,០ |
| អភិវឌ្ឍន៍ជនបទ | ៣ ០៨៨,៩ | ៧៥៣,៤ | ១២,០ | ១ ៨៥៤,៩ | ៤៥២,៤ | ១២,០ |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | ១ ០២៩,៦ | ២៥១,១ | ៤,០ | ៦១៨,៣ | ១៥០,៨ | ៤,០ |
| **សរុប** | **៦ ១៧៧,៧** | **១ ៥០៦,៨** | **២៤,០** | **៣ ៧០៦,៥** | **៩០៤,៨** | **២៤,០** |

| | | | | | | |
|---|---|---|---|---|---|---|
| **ហេដ្ឋារចនាសម្ព័ន្ធ** | | | | | | |
| ដឹកជញ្ជូន( ផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក អាកាសចរណ៍ ) | ៣ ០៨៨,៩ | ៧៥៣,៤ | ១២,០ | ១ ៨៥៤,៩ | ៤៥២,៤ | ១២,០ |
| ទឹកនិងអនាម័យ ( មិនគិតនៅជនបទ) | ១ ០២៩,៦ | ២៥១,១ | ៤,០ | ៦១៨,៣ | ១៥០,៨ | ៤,០ |
| ថាមពលនិងអគ្គិសនី | ១ ០២៩,៦ | ២៥១,១ | ៤,០ | ៦១៨,៣ | ១៥០,៨ | ៤,០ |
| ប្រៃសណីយ៍និងទូរគមនាគមន៍ | ២៥៧ ៤ | ៦២,៨ | ១,០ | ១៥៤,៦ | ៣៧,៧ | ១,០ |
| **សរុប** | **៥ ៤០៥,៥** | **១ ៣១៨,៤** | **២១,០** | **៣ ២៤៦,២** | **៧៩១,៧** | **២១,០** |
| **សេវាកម្មនិងកម្មវិធីអន្តរវិស័យ** | | | | | | |
| ការបញ្ជ្រាបយេនឌ័រ | ៣៨៦,១ | ៩៤,២ | ១,៥ | ២៣១,៨ | ៥៦,៥ | ១,៥ |
| ទេសចរណ៍ | ៥១៤,៨ | ១២៥,៦ | ២,០ | ៣០៩,១៥ | ៧៥,៤ | ២,០ |
| បរិស្ថាននិងការអភិរក្ស | ១ ០២៩,៦ | ២៥១,១ | ៤,០ | ៦១៨,៣ | ១៥០,៨ | ៤,០ |
| សហគមន៍និងសេវាកម្មសង្គម | ១ ០២៩,៦ | ២៥១,១ | ៤,០ | ៦១៨,៣ | ១៥០,៨ | ៤,០ |
| វប្បធម៌និងសិល្បៈ | ៣៨៦,២ | ៩៤,២ | ១,៥ | ២៣១,៨ | ៥៦,៥ | ១,៥ |
| អភិបាលកិច្ចនិងរដ្ឋបាល | ២ ០៥៩,២ | ៥០២,២ | ៨,០ | ១ ២៣៦,៦ | ៣០១,៦ | ៨,០ |
| **សរុប** | **៥ ៤០៥,៥** | **១ ៣១៨,៤** | **២១,០** | **៣ ២៤៦,២** | **៧៩១,៧** | **២១,០** |
| មិនទាន់បែងចែក | ៥១៤,៨ | ១២៥,៦ | ២,០ | ៣០៩,១៥ | ៧៥,៤ | ២,០ |
| **សរុបរួម** | **២៥ ៧៤០,៦** | **៦ ២៧៨,២** | **១០០,០** | **១៥ ៤៥៧,៩** | **៣ ៧៧០,២** | **១០០,០** |

## ១. សេចក្តីសង្ខេបនៃគម្រោងសម្រាប់ កវស បីឆ្នាំរំកិល២០១២-២០១៤ ដែលបានទទួលពីក្រសួង ស្ថាប័ន

៣០. *កវស បីឆ្នាំរំកិល២០១២-២០១៤* បានរៀបចំឡើងដោយមានមូលដ្ឋានលើធាតុចូលដែលបានទទួលពីគ្រប់ក្រសួង ស្ថាប័ន រួមមាន៖ *(១) គម្រោងកំពុងដំណើរការ* ជាគម្រោងដែលកំពុងអនុវត្តដោយមានឬពុំមានកិច្ចសហការប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និង *(២) គម្រោងសម្រាប់អនុវត្ត ផយអជ (គម្រោងថ្មី)* ដែលក្រសួង ស្ថាប័ន មានគម្រោងអនុវត្តក្នុងអំឡុងពេលឆ្នាំ២០១២-២០១៤។ *ផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣* បានចែងថា បរិមាណថវិកាចំនួន ៦ ២៧៨,១លានដុល្លារអាមេរិក នឹងត្រូវចំណាយសម្រាប់តម្រូវការវិនិយោគវិស័យសាធារណៈសម្រាប់រយៈពេល៥ឆ្នាំ២០០៩-២០១៣ ចំណែកឯតម្រូវការវិនិយោគវិស័យសាធារណៈនៃ *កវស បីឆ្នាំរំកិល ២០១២-២០១៤* មានចំនួន៣ ៧៧០,២លានដុល្លារអាមេរិក។ ក៏ប៉ុន្តែ ក្រសួង ស្ថាប័ន ស្នើសុំសម្រាប់ដាក់បញ្ចូលទៅក្នុង *កវស បីឆ្នាំរំកិល២០១២-២០១៤* មានចំនួន៤ ៨៩០,៣លានដុល្លារអាមេរិក។ ព័ត៌មានសង្ខេបស្តីពីគម្រោង *កវស បីឆ្នាំរំកិល២០១២-២០១៤* ដែលបានស្នើឡើងដោយក្រសួង ស្ថាប័ន មានបង្ហាញនៅក្នុងតារាងទី៨៖

- តម្រូវការចំណាយប៉ាន់ស្មានសរុបសម្រាប់ *កវស បីឆ្នាំរំកិល២០១២-២០១៤* តម្រូវការថវិកាសរុប៤ ៨៩០,៣លានដុល្លារអាមេរិក
    - គម្រោងកំពុងដំណើរការ២ ០៨៣,៥លានដុល្លារអាមេរិក

- គម្រោងសម្រាប់អនុវត្ត ផយអជ(ថ្មី)  ២ ៨០៦,៨លានដុល្លារអាមេរិក

o បរិមាណថវិកាដែលក្រសួងស្ថាប័នបានរាយការណ៍ថា បានសន្យាផ្តល់២ ២៨២,៥លានដុល្លារអាមេរិក
  - ថវិកាជាតិ ៣៤៣,២លានដុល្លារអាមេរិក
  - ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ១ ៩៣៩,៣លានដុល្លារអាមេរិក
  - សម្រាប់គម្រោងកំពុងដំណើរការ ១ ៨០០,២លានដុល្លារអាមេរិក
    - ថវិកាជាតិ ២៧១,១លានដុល្លារអាមេរិក
    - ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ១ ៥២៩,១លានដុល្លារអាមេរិក
  - សម្រាប់គម្រោងអនុវត្ត ផយអជ(ថ្មី) ៤៨២,៣លានដុល្លារអាមេរិក
    - ថវិកាជាតិ ៧២,១លានដុល្លារអាមេរិក
    - ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ៤១០,២លានដុល្លារអាមេរិក

o តម្រូវការថវិកាបំពេញបន្ថែម(បំពេញបន្ថែមបរិមាណហិរញ្ញប្បទានដែលបានសន្យា) ២ ៦០៧,៨លានដុល្លារអាមេរិក
  - គម្រោងកំពុងដំណើរការ ២៨៣,៣លានដុល្លារអាមេរិក
  - គម្រោងសម្រាប់អនុវត្ត ផយអជ ២ ៣២៤,៥លានដុល្លារអាមេរិក

៣១. តារាងទី៩ នឹងធ្វើការបង្ហាញលម្អិតបន្ថែមនូវគម្រោងដែលក្រសួង ស្ថាប័នទាំងអស់ បានផ្ញើមកក្រសួងផែនការសម្រាប់ធ្វើការរៀបចំ *កវស បីឆ្នាំរំកិល២០១២-២០១៤* និងបានបែងចែកគម្រោងទាំងអស់នោះទៅតាមវិស័យអាទិភាពរបស់ *ផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣*។ ព័ត៌មានគម្រោងទាំងនោះរួមមាន (i) តម្រូវការចំណាយប៉ាន់ស្មានសរុបទៅតាមឆ្នាំនីមួយៗពីឆ្នាំ២០១២ដល់២០១៤ (ii) បរិមាណហិរញ្ញប្បទានដែលក្រសួង ស្ថាប័នបានរាយការណ៍ថា បានសន្យាផ្តល់(ដោយរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ) សម្រាប់គម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្ត ផយអជ និង(iii) បរិមាណតម្រូវការហិរញ្ញប្បទានបំពេញបន្ថែមលើហិរញ្ញប្បទានដែលបានសន្យាផ្តល់រួចហើយក្នុងឆ្នាំនីមួយៗ។

## តារាងទី៨ សេចក្តីសង្ខេបស្តីពីគម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្ត ផយអជ ដែលក្រសួង ស្ថាប័នស្នើសុំសម្រាប់ ករស បីឆ្នាំរំកិល២០១២-២០១៤

(គិតជាពាន់ដុល្លារអាមេរិក)

| | ចំណាយប៉ាន់ស្មានសរុប | | | | ហិរញ្ញប្បទានបានសន្យាផ្តល់ | | | | | តម្រូវការហិរញ្ញប្បទានបំពេញបន្ថែម | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១២ | ២០១៣ | ២០១៤ | សរុប ២០១២-២០១៤ | ប្រភពហិរញ្ញប្បទាន | ២០១២ | ២០១៣ | ២០១៤ | សរុប ២០១២-២០១៤ | ២០១២ | ២០១៣ | ២០១៤ | សរុប ២០១២-២០១៤ |
| គម្រោងកំពុងដំណើរការ | 895,252.5 | 710,853.7 | 477,350.3 | 2,083,556.5 | រាជរដ្ឋាភិបាល | 103,809.6 | 87,457.1 | 79,846.2 | 271,113.0 | 90,560.8 | 90,782.6 | 102,064.0 | 283,307.4 |
| | | | | | ដៃគូអភិវឌ្ឍ | 700,982.1 | 532,614.1 | 295,440.0 | 1,529,136.2 | | | | |
| | | | | | សរុប | 804,791.7 | 620,071.2 | 375,286.3 | 1,800,249.1 | | | | |
| គម្រោងសម្រាប់អនុវត្ត ផយអជ | 750,659.0 | 1,021,675.9 | 1,034,429.1 | 2,806,764.1 | រាជរដ្ឋាភិបាល | 31,465.4 | 21,403.2 | 19,211.2 | 72,079.8 | 616,391.0 | 873,240.1 | 834,888.4 | 2,324,519.5 |
| | | | | | ដៃគូអភិវឌ្ឍ | 102,802.6 | 127,032.6 | 180,329.6 | 410,164.8 | | | | |
| | | | | | សរុប | 134,268.0 | 148,435.8 | 199,540.8 | 482,244.6 | | | | |
| **សរុប** | 1,646,011.5 | 1,732,529.7 | 1,511,779.5 | 4,890,320.6 | រាជរដ្ឋាភិបាល | 135,275.1 | 108,860.3 | 99,057.4 | 343,192.8 | 706,951.8 | 964,022.7 | 936,952.4 | 2,607,826.9 |
| | | | | | ដៃគូអភិវឌ្ឍ | 803,784.7 | 659,646.7 | 475,769.6 | 1,939,301.0 | | | | |
| | | | | | សរុប | 939,059.7 | 768,507.0 | 574,827.0 | 2,282,493.7 | | | | |

## តារាងទី៩ គម្រោងកំពុងដំណើរការ និងគម្រោងសម្រាប់អនុវត្ត ផយអជ បែងចែកទៅតាមវិស័យអាទិភាព នៃ ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ដែលក្រសួង ស្ថាប័នស្នើសុំ

*(គិតជា ពាន់ដុល្លារអាមេរិក)*

៣២. ដើម្បីធ្វើការវិភាគតម្រូវការចំណាយប៉ាន់ស្មានសម្រាប់វិនិយោគសាធារណៈដែលបានផ្ដល់ដោយក្រសួង ស្ថាប័ន តាមវិស័យក្នុង *ផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣* ដូចមានបញ្ជាក់ក្នុងកថាខណ្ឌមុននេះនិងតារាងទី៩ គម្រោងរបស់ក្រសួង ស្ថាប័នទាំងអស់ត្រូវបានបែងចែកទៅតាមវិស័យអាទិភាព ដោយផ្អែកលើសកម្មភាពសំខាន់ៗនៃគម្រោង។ ជាក់ស្ដែងព័ត៌មានគម្រោងបានបង្ហាញពីបរិមាណខុសគ្នាលើតម្រូវការចំណាយទៅតាមវិស័យដែលបានផ្ដល់ដោយក្រសួង ស្ថាប័ន និងការវិភាជតាមវិស័យ អនុវិស័យ ដែលមានចែងនៅក្នុង *ផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣*។

**តារាងទី១០ បរិមាណខុសគ្នានៃការវិភាជតាមអនុវិស័យក្នុង ផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣**

*(គិតជាលានដុល្លារអាមេរិក)*

| អនុវិស័យក្នុង ផយអជ បច្ចុប្បន្នកម្ម | វិភាជន៍អនុវិស័យ ក្នុង ផយអជ បច្ចុប្បន្នកម្ម សម្រាប់២០១២-២០១៤ | តម្រូវការចំណាយប៉ាន់ស្មានសរុប២០១២-២០១៤ | |
|---|---|---|---|
| | | ក្រសួង ស្ថាប័ន | បរិមាណ |
| សុខាភិបាល | | ក្រសួងសុខាភិបាល | ៣០៦.៥ |
| | | អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | ២១៣.៧ |
| | ៤៥២.៤ | **សរុប** | **៥២០.២** |
| អភិវឌ្ឍន៍ជនបទ | | ក្រសួងអភិវឌ្ឍន៍ជនបទ | ២៥២.១ |
| | | ក្រសួងធនធានទឹកនិងឧតុនិយម | ៨៨២.៤ |
| | ៤៥២.៤ | **សរុប** | **១ ១៣៤.៥** |
| ការដឹកជញ្ជូន | | ក្រសួងសាធារណការនិងដឹកជញ្ជូន | ១ ៧១១.០ |
| | | រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | ៥៤.៧ |
| | ៤៥២.៤ | **សរុប** | **១ ៧៦៥.៧** |
| **សរុប អនុវិស័យ ផយអជ បច្ចុប្បន្នកម្ម** | **១ ៣៥៧.២** | | **៣ ៤២០.៤** |

៣៣. ភាពប្រឈមនានាក្នុងការរៀបចំ *កវស បីឆ្នាំរំកិល២០១២-២០១៤* គឺមានភាពខុសគ្នាទៅនឹង *កវស បីឆ្នាំរំកិល២០១១-២០១៣* ក្នុងការជ្រើសរើសគម្រោង ការបញ្ចូលគម្រោងសម្រាប់អនុវត្តឲ្យបានត្រឹមត្រូវទៅតាមអាទិភាពនិងការវិភាជសម្រាប់តម្រូវការចំណាយ វិនិយោគវិស័យសាធារណៈដែលមានចែងនៅក្នុង *ផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣*។ បញ្ហាប្រឈមនេះ រួមផ្សំជាមួយនឹងគុណភាពនៃព័ត៌មានគម្រោងដែលក្រសួង ស្ថាប័នបានផ្ញើមកក្រសួងផែនការ។ តាមរយៈការពិនិត្យមើលឡើងវិញ បានបង្ហាញនូវការចាប់អារម្មណ៍ចំពោះបរិមាណថវិកា ដែលបានសន្យាផ្ដល់ដោយរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍរបស់ក្រសួង ស្ថាប័នមួយចំនួន ដែលក្នុងនោះ តាមការព្យាករនៅក្នុង

*ផយអជ បច្ចុប្បន្នកម្ម* រាជរដ្ឋាភិបាលមានលទ្ធភាពផ្តល់ថវិកាសម្រាប់វិនិយោគមូលធនវិស័យសាធារណៈប្រមាណ១ ០០៨,៣លានដុល្លារអាមេរិក ក៏ប៉ុន្តែ ក្រសួង ស្ថាប័នកត់ត្រាមានចំនួនប្រមាណ៣៤៣,២លានដុល្លារអាមេរិក និងតម្រូវការចំណាយសម្រាប់ *កវស បីឆ្នាំរំកិល២០១២-២០១៤* មានចំនួន៣ ៧៧០,២លានដុល្លារអាមេរិក។

**តារាងទី១១ សេចក្តីសង្ខេបការវិភាជតាមវិស័យក្នុង ផយអជ បច្ចុប្បន្នកម្ម និងចំណាយប៉ាន់ស្មានតាមក្រសួង ស្ថាប័ន**

*(គិតជាលានដុល្លារអាមេរិក)*

| វិស័យក្នុង ផយអជ បច្ចុប្បន្នកម្ម | វិភាជន៍តាមវិស័យក្នុង ផយអជ បច្ចុប្បន្នកម្ម សម្រាប់២០១២-២០១៤ | | | ចំណាយប៉ាន់ស្មានសរុបតាមក្រសួង[1] | ហិរញ្ញប្បទានដែលចុះកិច្ចសន្យាផ្តល់រួចហើយ | | តម្រូវការហិរញ្ញប្បទានបំពេញបន្ថែម |
|---|---|---|---|---|---|---|---|
| | សរុប | ថវិកាជាតិ | ដៃគូអភិវឌ្ឍ | | ប្រភពហិរញ្ញប្បទាន | បរិមាណ | |
| វិស័យសង្គមកិច្ច | ១ ២០៦,៥ | ៣២២,៦ | ៨៨៣,៨ | ៨៦០,៦ | ថវិកាជាតិ | ៤៣,១ | ៤៦៥,៩ |
| | | | | | ដៃគូអភិវឌ្ឍ | ៣៥១,៤ | |
| | | | | | សរុប | ៣៩៤,៥ | |
| វិស័យសេដ្ឋកិច្ច | ៩០៤,៨ | ២៤២,០ | ៦៦៣,០ | ១ ៣៨៩,១ | ថវិកាជាតិ | ១៨៦,៨ | ៤៥៦,៧ |
| | | | | | ដៃគូអភិវឌ្ឍ | ៧៤៥,៦ | |
| | | | | | សរុប | ៩៣២,៤ | |
| ហេដ្ឋារចនាសម្ព័ន្ធ | ៧៩១,៧ | ២១១,៨ | ៥៨០,០ | ២ ១៧៨,៣ | ថវិកាជាតិ | ៦៩,៥ | ១ ៣៨២,៣ |
| | | | | | ដៃគូអភិវឌ្ឍ | ៧២៦,៥ | |
| | | | | | សរុប | ៧៩៦,០ | |
| សេវាកម្មនិងកម្មវិធីអន្តរវិស័យ | ៧៩១,៧ | ២១១,៨ | ៥៨០,០ | ៣០៩,៣ | ថវិកាជាតិ | ១៧,៦ | ១៩៦,១ |
| | | | | | ដៃគូអភិវឌ្ឍ | ៩៥,៦ | |
| | | | | | សរុប | ១១៣,២ | |
| មិនបានបែងចែក | ៧៥,៤ | ២០,១ | ៥៥,២ | ១៥២,៩ | | ៤៦,២ | ១០៦,៧ |
| **គ្រប់វិស័យ** | **៣ ៧៧០,២** | **១ ០០៨,៣** | **២ ៧៦២,០** | **៤ ៨៩០,៣** | **ថវិកាជាតិ** | ៣៤៣,២ | **២ ៦០៧,៨** |
| | | | | | **ដៃគូអភិវឌ្ឍ** | ១ ៩៣៩,៣ | |
| | | | | | **សរុប** | **២ ២៨២,៥** | |

*ប្រភព ៖ តារាងទី៩*

៣៤. ដោយផ្អែកលើបទពិសោធន៍នៃការរៀបចំ *កវស បីឆ្នាំរំកិល២០១២-២០១៤* នេះ រាជរដ្ឋាភិបាលកម្ពុជា បានកត់សំគាល់ឃើញនូវចំណុចខ្វះខាតមួយចំនួន ដូចខាងក្រោម៖

- ក្រសួង ស្ថាប័នមួយចំនួនពុំបានផ្តល់ ព័ត៌មានស្តីពីការកំណត់អាទិភាពដល់គម្រោងសម្រាប់អនុវត្ត ផយអជ ដែលអាចសន្និតបានថា *ក)* ពុំទាន់បានរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យដែលកំណត់អំពីសកម្មភាពនានាដែលត្រូវអនុវត្តក្នុងក្របខ័ណ្ឌការងារដែលបង្ហាញពីទំនាក់ទំនងគ្នារវាងសកម្មភាពនិងដំណាក់កាលនៃការអនុវត្តដើម្បីសម្រេចបានគោលដៅចែងនៅក្នុង ផយអជ ឬ *ខ)* កង្វះខាតការចូលរួមរបស់ថ្នាក់ដឹកនាំក្នុងការជ្រើសរើសនិងការកំណត់អាទិភាពរបស់គម្រោងសម្រាប់ អនុវត្ត ផយអជ នៅតាមក្រសួង ស្ថាប័ន។
- ការប៉ាន់ស្មានពីតម្រូវការចំណាយរបស់គម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្ត ផយអជ ព្រមទាំងរបាយការណ៍អំពីបរិមាណថវិកាដែលបានចំណាយដោយក្រសួង ស្ថាប័ន គឺបង្ហាញពីកង្វះខាតការសម្របសម្រួលរបស់មន្រ្តីទទួលបន្ទុកការងារផែនការជាមួយមន្រ្តីផ្នែកគ្រប់គ្រងហិរញ្ញវត្ថុនិងមន្រ្តីគ្រប់គ្រងគម្រោងអភិវឌ្ឍន៍របស់ក្រសួង ស្ថាប័នទាំងនោះ។

## ២. កវស បីឆ្នាំរំកិល២០១២-២០១៤

៣៥. ដូចមានចែងនៅក្នុង *ផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣* តម្រូវការចំណាយសម្រាប់វិនិយោគវិស័យសាធារណៈរបស់ *កវស បីឆ្នាំរំកិល២០១២-២០១៤* មានចំនួន៣ ៧៧០,២លានដុល្លារអាមេរិក ដែលមានប្រភពមកពី៖

- រាជរដ្ឋាភិបាលកម្ពុជាចំនួន ១ ០០៨,២លានដុល្លារអាមេរិក
- ដៃគូអភិវឌ្ឍចំនួន ២ ៧៦២,០លានដុល្លារអាមេរិក។

៣៦. នីតិវិធីសម្រាប់ធ្វើការជ្រើសរើសគម្រោងដាក់បញ្ចូលទៅក្នុង *កវស បីឆ្នាំរំកិល២០១២-២០១៤* បានធ្វើឡើងតាមគោលការណ៍ ដូចខាងក្រោម៖

- អាទិភាពទី១ ត្រូវបានផ្តល់សម្រាប់ការវិភាជថវិកាដល់ការអនុវត្ត*គម្រោងកំពុងដំណើរការ*។
- អាទិភាពទី២ ត្រូវបានផ្តល់ចំពោះ *គម្រោងសម្រាប់អនុវត្ត ផយអជ* ដែលមានការសន្យាផ្តល់ហិរញ្ញប្បទានដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានធ្វើការពិនិត្យនិងកែសម្រួលបរិមាណថវិកាដែលបានសន្យាផ្តល់ដោយរាជរដ្ឋាភិបាលកម្ពុជា(*ក្នុងបរិបទនៃផែនការយុទ្ធសាស្រ្តថវិកាសម្រាប់ក្រសួង ស្ថាប័ន*) ដោយត្រូវធានាថាតម្រូវការចំណាយសរុបសម្រាប់*គម្រោងកំពុងដំណើរការ* និង*គម្រោងសម្រាប់អនុវត្ត ផយអជ* សម្រាប់វិស័យនីមួយៗត្រូវមានសង្គតិភាពជាមួយការវិភាជតាមវិស័យក្នុង *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣*។

ο អាទិភាពទី៣ ត្រូវផ្តល់ចំពោះ*គម្រោងសម្រាប់អនុវត្ត ផយអជ* ដែលមិនមានការសន្យាផ្តល់ហិរញ្ញប្បទាន។

៣៧. បញ្ជី *គម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្ត ផយអជ* ដែលក្រសួង ស្ថាប័ន បានដាក់បញ្ចូលទៅក្នុង *កវស បីឆ្នាំរំកិល២០១២-២០១៤* មានបង្ហាញក្នុងតារាងទី១២។ ការវិភាជថវិការបស់គម្រោង មានដូចខាងក្រោម៖

ο *៤២,៦ភាគរយ* នៃតម្រូវការចំណាយវិនិយោគសាធារណៈសរុប នឹងត្រូវវិភាជចំពោះការអនុវត្ត*គម្រោងកំពុងដំណើរការ*។

ο *៥៧,៤ភាគរយ* នៃតម្រូវការចំណាយវិនិយោគសាធារណៈសរុបនឹងត្រូវវិភាជចំពោះ *គម្រោងសម្រាប់អនុវត្ត ផយអជ*។

៣៨. តាមវិស័យក្នុង *ផយអជ បច្ចុប្បន្នកម្ម* គម្រោងក្នុង *កវស បីឆ្នាំរំកិល២០១២-២០១៤* មានការវិភាជតាមវិស័យដូចខាងក្រោម៖

ο ១៧,៦ភាគរយនៃតម្រូវការចំណាយវិនិយោគសាធារណៈសរុប សម្រាប់អនុវត្តគម្រោងក្នុងវិស័យសង្គមកិច្ច។

ο ២៨,៤ភាគរយនៃតម្រូវការចំណាយវិនិយោគសាធារណៈសរុប សម្រាប់អនុវត្តគម្រោងក្នុងវិស័យសេដ្ឋកិច្ច។

ο ៤២,០ភាគរយនៃតម្រូវការចំណាយវិនិយោគសាធារណៈសរុប សម្រាប់អនុវត្តគម្រោងក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ។

ο ៩,០ភាគរយនៃតម្រូវការចំណាយវិនិយោគសាធារណៈសរុប សម្រាប់អនុវត្តគម្រោងក្នុងវិស័យសេវាកម្មនិងកម្មវិធីអន្តរវិស័យ។

៣៩. ដើម្បីសម្រួលដំណើរការនៃការរៀបចំធាតុចូលពីគ្រប់ក្រសួង ស្ថាប័ន សម្រាប់ការរៀបចំ *កវស បីឆ្នាំរំកិល ២០១២-២០១៤* និងការសម្រេចចិត្តសម្រាប់ការវិភាជថវិកា ក្រសួងផែនការសូមអនុញ្ញាតផ្តល់អនុសាសន៍ដូចខាងក្រោម៖

ο ក្នុងវិស័យសង្គមកិច្ច កម្រិតតម្រូវការចំណាយវិនិយោគសាធារណៈក្នុងវិស័យអប់រំសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈនិងបច្ចេកទេស និងកម្មវិធីកាត់បន្ថយឥទ្ធិពលមិនល្អពីវិបត្តិហិរញ្ញវត្ថុសកលលោកលើប្រជាជនក្រីក្រនិងប្រជាជនងាយរងគ្រោះ គួរពិនិត្យបង្កើនបរិមាណតម្រូវការឲ្យដល់កម្រិតគោលដៅដែលមានចែងនៅក្នុងការវិភាជថវិកាតាមវិស័យ និងអនុវិស័យក្នុង *ផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣*។ ក្នុងវិស័យសុខាភិបាល ទោះបីតម្រូវការមានទំហំធំក៏ដោយ ក៏ត្រូវរក្សានូវតុល្យភាពរវាងតម្រូវការ និងការកំណត់

ការវិភាជ។ ដំណើរការនៃការរៀបចំព័ត៌មានគម្រោងរបស់ក្រសួងសុខាភិបាល និងអាជ្ញាធរ អេដស៍ គួរពិនិត្យសម្រួលជាមួយគ្នាដូចបានលើកឡើងក្នុងកថាខណ្ឌទី៣៤។

- ក្នុងវិស័យសេដ្ឋកិច្ច ចាំបាច់ត្រូវដោះស្រាយបញ្ហានានាដែលបានលើកឡើងក្នុងកថាខ័ណ្ឌ ទី៣៤ ដើម្បីពង្រឹងគុណភាព *កវស បីឆ្នាំរំកិល* ពេលអនាគត ត្រូវមានការសម្របសម្រួលឲ្យ មានភាពប្រសើរជាងមុននៅតាមក្រសួង ស្ថាប័ននៅក្នុងវិស័យនីមួយៗ។
- ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ការផ្ញើគម្រោងរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន គឺជា ឧទាហរណ៍មួយសម្រាប់បង្ហាញពីបញ្ហានានាដែលបានលើកឡើងក្នុងកថាខណ្ឌទី៣៤។
- ក្នុងវិស័យសេវាកម្មនិងកម្មវិធីអន្តរវិស័យ លើកលែងក្រសួង ស្ថាប័នមួយចំនួន កម្រិត ចំណាយប៉ាន់ស្មានគួរកំណត់ឲ្យបានសមរម្យពីកម្រិតនៅឆ្នាំ២០១២-២០១៤ ដោយមានការ គាំទ្រត្រូវចំគោលដៅសម្រាប់វិស័យអភិបាលកិច្ចនិងរដ្ឋបាល ព្រមទាំងសម្រាប់ការងារ បញ្ជ្រាបយេនឌ័រ។

# ជំពូកទី៤
# សេចក្តីសន្និដ្ឋាន

៤០. សម្រាប់ការរៀបចំ *កវស បីឆ្នាំរំកិល២០១២-២០១៤* ក្រសួងផែនការបានធ្វើការកែលម្អវិធីសាស្ត្រនៃការរៀបចំរបស់ខ្លួនតាមរយៈ (១) ការរៀបចំបញ្ជីសំណួរ *កវស* ឡើងវិញ (២) ការរៀបចំនិងការអនុវត្តប្រព័ន្ធទិន្នន័យមូលដ្ឋានថ្មី និង (៣) ព្រមទាំងដំណើរការប្រមូលទិន្នន័យ *កវស* ពីក្រសួង ស្ថាប័ននានាដែលត្រូវបានរៀបចំដោយស្វ័យប្រវត្តិដើម្បីកាត់បន្ថយកំហុសនិងពេលវេលាក្នុងការបញ្ចូលទិន្នន័យ។ ក្រសួងផែនការបានផ្ញើបញ្ជីសំណួរជា*ស៊ីឌីរ៉ូម*(CD-ROM) ដល់គ្រប់ក្រសួង ស្ថាប័ន ដើម្បីសម្រួលដល់ការបំពេញនិងការប្រមូលព័ត៌មានពីក្រសួង ស្ថាប័ន។

៤១. ដំណើរការនៃការកែលម្អការរៀបចំ *កវស បីឆ្នាំរំកិល* គឺជាសកម្មភាពដែលកំពុងនិងបន្តអនុវត្ត។ ការកែលម្អនេះ ត្រូវបាននិងកំពុងដឹកនាំនិងត្រួតពិនិត្យដោយ *ក្រុមការងារដឹកនាំដំណើរការសុខដុមនីយកម្មការងារផែនការចំណាយវិនិយោគសាធារណៈរបស់រដ្ឋនិងហិរញ្ញប្បទានសហប្រតិបត្តិការ* ដែលក្រុមការងារនេះបានដឹកនាំដោយក្រសួងផែនការ ហើយការងារនេះជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី២របស់រាជរដ្ឋាភិបាល។

៤២. ដើម្បីរៀបចំគម្រោង *កវស បីឆ្នាំរំកិល* ឲ្យមានភាពសុក្រឹតថែមទៀត រាជរដ្ឋាភិបាលកម្ពុជាសូមធ្វើការណែនាំដល់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវ៖

- ចាត់តាំងមន្ត្រីទទួលបន្ទុកការងារផែនការឲ្យបានច្បាស់លាស់និងធ្វើការបណ្តុះបណ្តាលបន្តដល់មន្ត្រីទទួលបន្ទុកថ្មី បន្ទាប់ពីមានការផ្លាស់ប្តូរមន្ត្រីចាស់។
- រៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ដើម្បីមានភាពងាយស្រួលក្នុងការវិភាជថវិកាសម្រាប់គម្រោងក្នុងវិស័យនោះ។
- បង្កើតក្រុមការងារ ដើម្បីតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់របាយការណ៍ស្តីពីស្ថានភាពអនុវត្តគម្រោងរបស់ខ្លួនដែលមានក្នុង *កវស បីឆ្នាំរំកិល* នាឆ្នាំកន្លងទៅជូនក្រសួងផែនការ។
- មានកិច្ចសហការល្អរវាងមន្ត្រីទទួលបន្ទុកការងារផែនការ មន្ត្រីផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ និងមន្ត្រីគ្រប់គ្រងគម្រោងអភិវឌ្ឍន៍ សម្រាប់ការរៀបចំគម្រោងរបស់ខ្លួនដើម្បីដាក់បញ្ចូលទៅក្នុង *កវស បីឆ្នាំរំកិល*។
- មានការចូលរួមពីថ្នាក់ដឹកនាំរបស់ក្រសួង ស្ថាប័ន ក្នុងការជ្រើសរើសនិងការកំណត់អាទិភាពគម្រោងនានារបស់ខ្លួន។
- ផ្តល់ទិន្នន័យគម្រោងជូនក្រសួងផែនការឲ្យបានតាមពេលវេលាកំណត់។